# ការអធិស្ឋាន
# គឺជាការនាំយកស្ថានសួគ៌មកផែនដី



**លោកដុកទ័រ អេអែល ហ្គីល** គឺជាកំពូលអ្នកនិពន្ធសៀវភៅជិត២០ លានក្បាល ដែលបានបោះពុម្ពហើយ ។ ការងារជាសាវ័កផ្នែកអន្តរជាតិរបស់គាត់នេះ គឺបានចាប់យកមនុស្សជាង៨០ជនជាតិ ។ គាត់បានអធិប្បាយទៅដល់ហ្វូងមនុស្សជាងម្ភៃម៉ឺននាក់ ដោយមានការបញ្ជាក់មកពីព្រះ និងព្រះបន្ទូលរបស់ព្រះអង្គ ជាមួយនឹងទីសម្គាល់នៃការប្រោសឱ្យជា និងការអស្ចារ្យផ្សេងៗ ។ ការអនុវត្តន៍ដែលមានពេញដោយអំណាចចេស្តារបស់គាត់ សេចក្តីបង្រៀនដែលមានពេញដោយជីវិតផ្លាស់ប្រែ និងដែលមានលទ្ធភាព នោះគឺតាមរយៈវីឌីអូ អូឌីយ៉ូ និងសៀវភៅជាច្រើនភាសា នោះសូមមើលទៅក្នុងវិបសាយ:www.gillministries.com

*១. ព្រះអម្ចាស់ទ្រង់បង្រៀនឱ្យចេះអធិស្ឋាន ............ ១៩១*
*២. ការអធិស្ឋានដែលមានជោគជ័យជាចាំបាច់ ........... ១៩៩*
*៣. ការអធិស្ឋានឱ្យនគរបានជឿនទៅមុខ ................ ២០៧*
*៤. សេចក្តីអធិស្ឋាន គឺជាសម្លេងនៃសេចក្តីជំនឿ........ ២១៣*
*៥. សេចក្តីជំនឿបំពេញលើសេចក្តីអធិស្ឋាន.............. ២២១*

# ការអធិស្ឋាន
# គឺជាការនាំយកស្ថានសួគ៌មកផែនដី
## *មេរៀនទី ១: ព្រះអម្ចាស់បង្រៀនយើងឱ្យចេះអធិស្ឋាន*

ព្រះគម្ពីរលូកា ១១:១-២ ម្យ៉ាងទៀត នៅពេលដែលព្រះយេស៊ូវទ្រង់បានចេញទៅអធិស្ឋាន សិស្សរបស់ទ្រង់ម្នាក់បានចេញមកឯទ្រង់ គឺនៅពេលដែលទ្រង់បានបង្ហើយការនោះ គាត់ក៏បានទូលថា "ព្រះអម្ចាស់អើយ សូមបង្រៀនយើងខ្ញុំឱ្យចេះអធិស្ឋានផង ដូចជាលោកយ៉ូហានបានបង្រៀនសិស្សរបស់គាត់ដែរ" ។ ទ្រង់ក៏មានបន្ទូលថា "អ្នកត្រូវអធិស្ឋានថា ឱព្រះវរបិតាអើយ សូមឱ្យព្រះនាមទ្រង់បានបរិសុទ្ធ សូមឱ្យរាជ្យទ្រង់បានមកដល់ឆាប់ៗ" ។

### I. តើសេចក្តីអធិស្ឋានជាអ្វី?

### ក. "ចូរនិយាយថា"

គ្មានអ្នកណាម្នាក់មានការរវល់ជាជាងព្រះយេស៊ូវទេ ។ ព្រះយេស៊ូវទ្រង់បានចំណាយពេលអធិស្ឋាន ដូច្នេះ យើងក៏ត្រូវចំណាលពេលអធិស្ឋានដែរ ។ ពួកសិស្សបានទទួលស្គាល់ថា ដើម្បីឱ្យបានដូចជាព្រះយេស៊ូវ នោះពួកគេត្រូវតែអធិស្ឋាន ។ ហេតុអ្វីបានជាពួកគេទូលសូមឱ្យព្រះយេស៊ូវ បង្រៀនពួកគេឱ្យចេះអធិស្ឋាន? ត្រូវតែមានការងារខ្លះសម្រាប់សម្គាល់ពីលក្ខណៈសំខាន់នៃការអធិស្ឋាន និងលទ្ធផលរបស់ព្រះយេស៊ូវ។ ក៏មានលក្ខណៈសំខាន់ខ្លះៗទៀត ពីសេចក្តីអធិស្ឋានរបស់ព្រះអង្គ ដែលមិនដូចលក្ខណៈសំខាន់នៃសេចក្តីអធិស្ឋានរបស់ពួកគេ ។ ការផ្លាស់ប្រែសេចក្តីសំខាន់នៃការអធិស្ឋានរបស់ខ្ញុំ គឺបានតម្រូវឱ្យផ្តង់ចិត្តដ៏ពិតទៅលើចំណែករបស់ខ្ញុំដែរ ។

នៅពេលដែលអ្នកអធិស្ឋាន អ្នកមិនត្រូវទូលសូមដល់ព្រះទេ ។ អ្នករាល់គ្នាត្រូវតែនិយាយទៅតាមបំណងព្រះហឫទ័យរបស់ព្រះ គឺមិនត្រូវនិយាយពីបញ្ហាទេ គឺត្រូវតែនិយាយដោយសេចក្ដីជំនឿលើព្រះវិញ ។ ចូរជឿថា អ្វីដែលលោកអ្នកនិយាយ នោះនឹងបានសម្រេច ។

ព្រះគម្ពីរម៉ាកុស ១១:២២-២៣

ខ្ញុំបានប្រើសេចក្ដីអធិស្ឋានដ៏វែងមួយ ដែលមានបញ្ជីបញ្ហាទាំងឡាយ ក្នុងការទូលប្រាប់ដល់ព្រះអំពីគ្រប់ការទាំងដែលខ្ញុំត្រូវការ ដោយមានការខ្វល់ខ្វាយ សង្ស័យ និងភ័យខ្លាច ។ បញ្ជីរបស់ខ្ញុំវែងកាន់តែវែងទៅៗ ពីព្រោះខ្ញុំបានទទួលនូវចម្លើយបន្តិចបន្តួចតែប៉ុណ្ណោះ ។ គឺមានតែផ្លូវដែលខ្ញុំត្រូវដកចេញខ្លះនូវបញ្ជីនៃសេចក្ដីអធិស្ឋានរបស់ខ្ញុំតែប៉ុណ្ណោះ ដែលត្រូវស្លាប់ ។

### ១. ចូរចាប់យកអំណាចគ្រប់គ្រង ។

យើងត្រូវចាប់យកអំណាចគ្រប់គ្រង ហើយទូលសូមឱ្យនគររបស់ព្រះឆាប់មកដល់ផែនដី តាមអ្វីដែលយើងនិយាយ នៅពេលដែលយើងអធិស្ឋាននោះ ។

ព្រះគម្ពីរលោកុប្បត្តិ ១:២៦-២៨

រឿងទីមួយ ដែលព្រះទ្រង់មានបន្ទូលបន្ទាប់ពីទ្រង់ បានបង្កើតមនុស្សជាតិមកថា "ចូរបង្កើតកូនឱ្យបានចម្រើនជាច្រើនឡើង" ។ ទាំងពីរនេះ គឺជាស្នាព្រះហស្តដែលដូចជាព្រះ គឺត្រូវឱ្យបានចម្រើនជាច្រើនឡើង ឱ្យបានពាសពេញលើផែនដី ព្រមទាំងបង្ក្រាបវា ឱ្យមានអំណាចគ្រប់គ្រងលើផែនដី និងគ្រប់របស់ទាំងអស់ដែលនៅលើវា គឺរួមបញ្ចូនទាំងសាតាំងផងដែរ ។

ព្រះគម្ពីរទំនុកដំកើង ៨:៤-៨

យើងរាល់គ្នាជាកូនរបស់ព្រះ ទាំងប្រុសទាំងស្រី ។ យើងត្រូវបានបង្កើតមកឱ្យទាមជាងទ្រង់ (អេឡូ-ហ៊ីម) គឺជាព្រះអង្គទ្រង់តែបន្តិចប៉ុណ្ណោះ ។ (ចូរចងចាំថា: ពាក្យដែលបានបកប្រែពី "ពួកទេវតា" នៅទីនេះ គឺជា "អេឡូហ៊ីម" ឬក៏ជាព្រះអង្គទ្រង់នោះឯង) ។ ព្រះទ្រង់បានប្រទានអំណាចគ្រប់គ្រងមកលើផែនដីនេះ ដើម្បី "ការកើតជាថ្មី" ទាំងនេះឯង គឺដែលបានបង្កើតមក ឱ្យមានរូបភាពរបស់ព្រះអង្គ គឺឱ្យមានភាពដូចជាអង្គទ្រង់ ព្រមទាំងឱ្យមានជីវិតរបស់ព្រះអង្គ ដែលនៅក្នុងពួកគេនោះឯង ។ ព្រះទ្រង់គឺជាស្ដេចលើអស់ទាំងស្ដេច ។ ដូច្នេះ យើងគឺជា "ស្ដេច" នៅលើផែនដីនេះ ក្នុងការគ្រប់គ្រង សោយរាជ្យ និងចាប់យកអំណាចគ្រប់គ្រងនៅទីនេះ គឺនៅលើភពផែនដីនេះតែម្ដង ។

### ២. អំណាចគ្រប់គ្រងត្រូវកែជាថ្មីឡើងវិញ

លោកអ័ដាម និងនាងអេវ៉ាបានបាត់បង់នូវអំណាចគ្រប់គ្រងនេះ គឺនៅពេលដែលពួកគេបានធ្វើបាប និងបានប្រគល់អំណាចគ្រប់គ្រងឱ្យទៅសាតាំងនោះឯង ។ ព្រះយេស៊ូវទ្រង់បានកែជាថ្មីឡើងវិញ នូវសិទ្ធិអំណាចដល់យើងជាពួកជំនុំរបស់ព្រះអង្គ នៅសម័យសព្វថ្ងៃនេះ ។ ទ្រង់បានចាប់យកកូនសោរពីដៃសាតាំង គឺនៅពេលដែលទ្រង់បានទទួលជ័យជម្នះលើសេចក្ដីស្លាប់ ស្ថាននរក និងផ្លូវ

នោះឯង ។ បន្ទាប់មក ព្រះយេស៊ូវទ្រង់បានកែកូនសោរនៃអំណាចគ្រប់គ្រងទាំងនោះ សារជាថ្មីឡើងវិញ ប្រគល់ទៅឱ្យពួកជំនុំ ។

ព្រះគម្ពីរម៉ាថាយ ១៦:១៨-១៩

ព្រះគម្ពីរលូកា ១០:១៩

ព្រះយេស៊ូវ ទ្រង់បានប្រទានដល់ពួកជំនុំរបស់ទ្រង់ នូវកូនសោរទាំងនោះហើយ ។ គឺជាសិទ្ធិអំណាច និងជាអំណាចគ្រប់គ្រងត្រូវបានរំដោះ តាមរយៈអ្វីដែលយើងនិយាយ ក្នុងពេលអធិស្ឋាននោះឯង ។ ទោះជាយ៉ាងណាក៏ដោយ ដែលយើងចងអ្វីៗនៅលើផែនដី នោះក៏ត្រូវនៅលើស្ថានសួគ៌ដែរ ។ បើយើងស្រាយអ្វីៗនៅលើផែនដី នោះយើងក៏ត្រូវស្រាយនៅឯស្ថានសួគ៌ដែរ ។ ទ្រង់បានកែជាថ្មីឡើងវិញ ទ្រង់បានប្រោសលោះមនុស្ស ឱ្យមានសិទ្ធិអំណាចលើសាតាំង និងពួកវិញ្ញាណអាក្រក់ និងអំណាចទាំងអស់របស់វាហើយ ។

## ខ. តើអ្វីទៅដែលយើងត្រូវ "និយាយ" នៅពេលយើងដែលយើងអធិស្ឋាន?

### ១. សេចក្តីអធិស្ឋានគឺមិនមែនជា:

ក. ការទូលប្រាប់ទៅព្រះពីបញ្ហារបស់យើងនោះទេ។

ខ. ការចង្អុលបង្ហាញដោយសង្ស័យ និងមិនជឿរបស់យើងនោះទេ ។

គ. ការសុំនោះទេ

ឃ. ការទុក្ខព្រួយនោះទេ

ង. ការប្រឡូងះ

១. ឱព្រះអង្គអើយ! ហេតុអ្វីបានជាទ្រង់បើកឱ្យអារក្សធ្វើការយ៉ាងនេះមកទូលបង្គំ?

២. ឱព្រះអង្គអើយ! តើទ្រង់សព្វព្រះហឫទ័យធ្វើអ្វីយ៉ាងនេះ?

៣. ចម្លើយរបស់ព្រះគឺ "គ្មានអ្វីសោះ" ។ តើទ្រង់បានធ្វើអ្វីយ៉ាងដូច្នេះ?

៤. ចម្លើយរបស់ព្រះគឺ "គ្មានអ្វីសោះ ។ តើទ្រង់បានធ្វើអ្វីយ៉ាងដូច្នេះ? ការងាររបស់ទូលបង្គំ គឺបានចប់សព្វគ្រប់អស់ហើយ ។

### ២. សេចក្តីអធិស្ឋានគឺជា:

ព្រះគម្ពីរសុភាសិត ១៨:២១

ព្រះគម្ពីរអេសាយ ៥៧:១៩

វាគឺជាការសំខាន់នូវអ្វីដែលយើងនិយាយ ក្នុងពេលដែលយើងអធិស្ឋាន ។ យើងត្រូវតែចាប់យកនូវអំណាចគ្រប់គ្រង តាមអ្វីដែលយើងនិយាយនោះ ។ ព្រះទ្រង់បានកែជាថ្មី នូវអំណាចគ្រប់គ្រងនោះដល់យើង គឺជាពួកជំនុំរបស់ព្រះអង្គ ។ តើអ្វីទៅដែលយើងនិយាយ នៅក្នុងសេចក្តីអធិស្ឋានរបស់យើង? តើពាក្យសម្តីដែលយើងបាននិយាយ នោះត្រូវស្លាប់នៅក្នុងសេចក្តីអធិស្ឋានរបស់យើងនោះឬអី? យើងត្រូវតែឈប់អធិស្ឋាន តាមរបៀបចាស់បុរាណរបស់យើង។ យើងត្រូវការនិយាយជារបៀបមានសុខភាព និងជារបៀបមានសេចក្តីចម្រុងចម្រើន ។ ព្រះទ្រង់គឺជាអ្នកបង្កើត ។ ទ្រង់បានបង្កើតយើងមកឱ្យមានរូបភាពរបស់ព្រះអង្គ ។ តើងត្រូវបានបង្កើតមក

ដោយការអធិស្ឋាន ពីការត្រាស់ហៅរបស់យើង ដូច្នោះឬ?

**គ. ព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌**

យើងត្រូវការការប្រកបស្និទ្ធស្នាល ជាមួយនឹងព្រះវរបិតារបស់យើង ។

ព្រះគម្ពីរកាឡាទី ៣:២៦

ព្រះគម្ពីរកាឡាទី ៤:៦-៧

ព្រះទ្រង់បានបង្កើតមនុស្សប្រុសស្រី និងបានត្រាស់ហៅពួកគេទាំងពីរជាកូនរបស់ព្រះអង្គ មិនមែនជាអ្នកបម្រើជាអ្នកស៊ីឈ្នួលរបស់ព្រះនោះទេ ។

ព្រះគម្ពីរអេភេសូរ ១:៣

យើងបានទទួលព្រះពរ ជាមួយនឹងព្រះពរខាងឯវិញ្ញាណនៅឯនគរស្ថានសួគ៌ ជាកន្លែងដែលព្រះគ្រីស្ទគង់នៅ ។ តើព្រះពរទាំងនេះគឺសម្រាប់តែពេល ដែលយើងបានទៅដល់ស្ថានសួគ៌នោះឬ? គឺដោយសេចក្តីអធិស្ឋាន ព្រះពរទាំងនេះបានត្រឡប់មកជារបស់យើងនៅថ្ងៃនេះ ។

ព្រះគម្ពីរសេផានា ៣:១៧

ព្រះទ្រង់កំពុងតែមានសេចក្តីអំណរ ជាមួយនឹងយើង ។ ហេតុអ្វីបានជាយើងរស់នៅពីក្រោមតួនាទីរបស់យើង នៅក្នុងព្រះគ្រីស្ទ?

ព្រះគម្ពីរភីលីព ៤:១៩

សេចក្តីត្រូវការរបស់យើងគឺនៅទីនេះ ក្នុងពេលឥឡូវនេះ ។ នឹងគ្មានសេចក្តីត្រូវការនៅឯស្ថានសួគ៌នោះទេ ។

ព្រះគម្ពីរយ៉ូហាន ១៤:១៣-១៤

**ឃ.តើយើងមកផែនដីជារបស់យើងដោយរបៀបណា?**

**១. ចូលមកតាមទ្វារដោយអរព្រះគុណ**

ព្រះគម្ពីរទំនុកដំកើង ១០០:៤

**២. ដោយការថ្វាយបង្គំ**

"សូមឱ្យព្រះនាមទ្រង់បានបរិសុទ្ធ" ។

ទូលបង្គំសូមលើកព្រះនាមទ្រង់ឡើង សូមឱ្យព្រះនាមទ្រង់បានបរិសុទ្ធ ។ សូមលើកតម្កើងព្រះយេហូវ៉ាជាមួយនឹងទូលបង្គំ ។ ការលើកតម្កើងព្រះគឺមិនមែនធ្វើឱ្យព្រះកាន់តែធំឡើងនោះទេ គឺធ្វើឱ្យភ្នែកយើងផ្ទាល់បានយល់ច្បាស់ថា តើព្រះទ្រង់ធំប៉ុណ្ណាតែប៉ុណ្ណោះ ។ ព្រះទ្រង់បានកែកូនសោរនៃអំណាចគ្រប់គ្រង ដល់ពួកជំនុំរបស់ទ្រង់នៅទីនេះ គឺនៅលើផែនដីនេះឯង ។

**ង. សូមឱ្យរាជ្យទ្រង់បានមកដល់!**

ព្រះគម្ពីរវិវរណៈ ១៩:១៦

ព្រះគម្ពីរ ២ធីម៉ូថេ២:១២ក

ព្រះគម្ពីរវិវរណៈ ៥:១០

**១. មកដល់!**

តាមពាក្យជាភាសាក្រិកៈ អឺកូមេហេ! គឺជាពាក្យបញ្ជា ។

**២. គំរូៈ**

ក. លោកពេត្រុសបានដើរលើទឹកៈ

ព្រះគម្ពីរម៉ាថាយ ១៤:២៨

នៅពេលដែលព្រះយេស៊ូវ ទ្រង់មានព្រះបន្ទូលថា "ចូរមក" គឺដូចគ្នានឹងពាក្យ "អឺកូមេ-

ហេ" (Ercomehe) ។ វាគឺជាពាក្យបញ្ជាថា "ចូរចេញមកពីទីនោះមកកាន់ទីនេះ!"

ខ. មេបញ្ជាការ:

ព្រះគម្ពីរម៉ាថាយ ៨:៥-១០

ម្យ៉ាងទៀតពាក្យ "អឺកូមេហេ" នេះគឺត្រូវបានគេប្រើនៅពេលបញ្ជា ជាពាក្យបញ្ជារបស់ពួកទាហានរ៉ូមបាននិយាយថា "ទូលបង្គំនិយាយទៅម្នាក់នេះថា ចូរទៅ នោះវាក៏ទៅ ចូរមកនោះវាក៏មក ..." ។

ដូច្នេះ ពាក្យ "ចូរមក" គឺជាពាក្យបញ្ជា គឺជាពាក្យ ដែលនិយាយដោយនូវសិទ្ធិអំណាច។

ព្រះយេស៊ូវ ទ្រង់បានធ្វើឱ្យមេបញ្ជាការនេះបានយល់ពីសិទ្ធិអំណាច ។

នេះគឺជាពាក្យដូចគ្នា ដែលយើងត្រូវតែប្រើនៅពេលដែលយើងអធិស្ឋាន ដោយការនិយាយថា "សូមឱ្យរាជ្យទ្រង់បានមកដល់!"

ព្រះគម្ពីររ៉ូម ៤:១៧

យើងត្រូវហៅរឿងទាំងនោះ ដែលមិនមាននោះឱ្យមានឡើង ។

### ច. លោកអ្នកនឹងធ្វើសម្រេចនៅផែនដីនេះ ដូចនៅស្ថានសួគ៌ដែរ!

បំណងព្រះហឫទ័យរបស់ព្រះ គឺបានសម្រេចនៅស្ថានសួគ៌ ប៉ុន្តែ គឺមិនមែនគឺមិនមែនបានសម្រេចនៅក្នុងតំបន់សិទ្ធិអំណាចរបស់យើងនោះទេ ល្គឹកណាតែយើងនិយាយពីការនេះពីព្រោះទ្រង់បានប្រទានមកយើង ដែលជាអ្នកជឿនូវសិទ្ធិអំណាចទាំងអស់នៅលើផែនដីនេះរួចទៅហើយ ។

ការអធិស្ឋាននេះចាប់ផ្តើមក្នុងការថ្វាយបង្គំ ដែលនៅក្នុងព្រះវត្តមានរបស់ព្រះវរបិតា ។ វាគឺជាការស្តាប់ឮពីព្រះវរបិតា ការសិក្សាក្នុងការចូលរួមពីនគររបស់ព្រះអង្គ ហើយបន្ទាប់មកគឺជាការនាំបំណងព្រះហឫទ័យរបស់ទ្រង់ ពីស្ថានសួគ៌មកផែនដីដែលនៅក្នុងតំបន់ ខាងសិទ្ធិអំណាចរបស់យើងដោយនូវអ្វី ដែលយើងបាននិយាយនៅពេលអធិស្ឋាននោះឯង ។ តាមរយៈការអធិស្ឋានដោយនូវសិទ្ធិអំណាច ការអធិស្ឋានដោយនូវអំណាចគ្រប់គ្រងដ៏ជឿនលឿនពីនគរ នោះយើងនឹងសោយរាជ្យជាស្តេចនៅលើផែនដីនេះហើយ ។ យើងម្នាក់ៗមានតំបន់សិទ្ធិអំណាច ហើយនៅក្នុងតំបន់នោះ ដែលយើងត្រូវតែប្រើអំណាចនោះឱ្យបានជឿនលឿន នៅក្នុងនគររបស់ព្រះ តាមអ្វីដែលយើងនិយាយនៅពេលអធិស្ឋាននោះ ។

ព្រះគម្ពីរម៉ាថាយ ១១:១២

## II. នគររបស់ផងព្រះ

### ក. តើអ្វីទៅជានគររបស់ផងព្រះ?

ព្រះគម្ពីររ៉ូម ១៤:១៧

**១. សេចក្តីសុចរិត**

ព្រះគម្ពីរម៉ាថាយ ៦:៣៣

ព្រះគម្ពីរ ២កូរិនថូស ៥:២១

ព្រះគម្ពីររ៉ូម ៨:១

**២. សេចក្តីសុខសាន្ត**

ព្រះគម្ពីរអេសាយ ៩:៦

ព្រះគម្ពីរកាឡាទី ៥:២២

ព្រះគម្ពីរភីលីព ៤:៦-៧

**៣. សេចក្តីអំណរ**

សេចក្តីអំណរគឺជាផលផ្លែផ្លែ នៃព្រះវិញ្ញាណបរិសុទ្ធដទៃ ទៀត ( កាឡាទី ៥:២២) ។

ព្រះគម្ពីរទំនុកដំកើង ១៦:១១

ព្រះគម្ពីរ ១ពេត្រុស ១:៨

**ខ. ការទទួលនិងការកាន់កាប់នគរ**

ព្រះគម្ពីរដានីយ៉ែល ៧:១៣-១៤,១៨,២៧

**គ. ការជឿនលឿនទៅមុខខាងនគរ**

ព្រះគម្ពីរម៉ាថាយ ២៤:១៤

ព្រះគម្ពីរលូកា ១០:៨

ព្រះគម្ពីរលូកា ១៧:២០-២១

**១. សូមឱ្យរាជ្យទ្រង់បានមកដល់!**

**២. សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេច!**

បំណងព្រះហឫទ័យទ្រង់គឺជា ...

ក. គ្មានសេចក្តីទុច្ចរិត

ខ. គ្មានការវិវាទ

គ. គ្មាន

ឃ. គ្មានជម្ងឺរោគា

ង. គ្មានសេចក្តីស្លាប់

ច. គ្មានភាពទ័លក្រ ឬការខ្វះខាត

ឆ. គ្មានការឡើងតុលាការក្នុងការលះលែង

**៣. ការអនុវត្តន៍**

ក. តើបំណងព្រះហឫទ័យរបស់ព្រះ បានសម្រេចនៅក្នុងតំបន់ខាងសិទ្ធិអំណាចរបស់យើងឬនៅ?

ខ. យើងត្រូវការសិក្សានូវការអធិស្ឋាន ដូចជាព្រះយេស៊ូវទ្រង់បានអធិស្ឋានដែរ ។

គ. ឱព្រះអម្ចាស់យេស៊ូវអើយ សូមបង្រៀនយើងខ្ញុំឱ្យចេះអធិស្ឋានផង ។

ឃ. សេចក្តីអធិស្ឋាន គឺនាំយកបំណងព្រះហឫទ័យរបស់ទ្រង់ មកក្នុងតំបន់នៃសិទ្ធិអំណាចរបស់យើងនៅលើផែនដីនេះ គឺឱ្យចូលមកក្នុងជីវិតរបស់យើង ក្នុងផ្ទះរបស់យើង ក្នុងអ្នកជិតខាងរបស់យើង ទីក្រុង ជនជាតិ ឬក៏គ្រប់កន្លែងទាំងអស់នោះរបស់យើង ដែលព្រះទ្រង់បញ្ជូនយើងមកនេះ ។ វាគឺជាការសំខាន់នូវអ្វីដែលយើង "និយាយ" ពេលអធិស្ឋាននោះ ។ "ឱព្រះវរបិតាអើយ! សូមឱ្យរាជ្យទ្រង់បានមកដល់ សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេច នៅផែនដី (គឺនៅក្នុងតំបន់សិទ្ធិអំណាចរបស់យើង) ដូចជានៅស្ថានសួគ៌ដែរ" ។

# ក្រុមពិភាក្សា

១. នៅពេលលោកអ្នកអធិស្ឋាន ហេតុអ្វីបានជាលោកអ្នកមិនត្រូវសុំដល់ព្រះ?

២. ប្រសិនបើព្រះទ្រង់មានសេចក្តីអំណរដល់យើង ហេតុអ្វីបានជាពួកគ្រីស្ទានខ្លះ បានរស់នៅទាបជាងតួនាទីរបស់ពួកគេនៅក្នុងព្រះគ្រីស្ទ?

៣. បន្ទាប់ពីបានសិក្សាពីពាក្យនោះមក "ចូរមក" គឺជាពាក្យបញ្ជានៅក្នុងព្រះគម្ពីររ៉ូម ៤:១៧ តើយើងត្រូវមានការផ្លាស់ប្រែពីមធ្យោបាយដែលត្រូវអធិស្ឋានយ៉ាងដូចម្តេច?

# ការសិក្សាដោយខ្លួនឯង

១. ចូរអានម្តងទៀត ហើយគិតអំពីប្រយោគជាបន្តបន្ទាប់ចេញពីមេរៀននេះ: "ទ្រង់បានកែជាថ្មីឡើងវិញ បានប្រោសលោះមនុស្ស ឱ្យមានសិទ្ធិអំណាចលើសាតាំង និងពពួកវិញ្ញាណអាក្រក់ទាំងអស់ ព្រមទាំងអំណាចរបស់វានោះ" ។

ក. តើការនេះមានន័យយ៉ាងដូចម្តេច? ចូរសរសេរនូវប្រយោគដោយនូវពាក្យពេចន៍ផ្ទាល់ របស់លោកអ្នកម្តងទៀត ។

ខ. តើការខិតខំប្រឹងប្រែងដ៏ពិតនេះ ធ្វើឱ្យមានការកែប្រែជីវិតរបស់លោកអ្នកពីចំណុចនេះ ដោយរបៀបណា?

២. ចូរគិតអំពីរបៀបដែលលោកអ្នកអធិស្ឋាន ។ តើលោកអ្នកបាននិយាយពីពាក្យស្លាប់ណាមួយ នៅក្នុងសេចក្តីអធិស្ឋានរបស់លោកអ្នកឬទេ? តើលោកអ្នកអាចបញ្ឈប់ការអធិស្ឋានតានរយៈទម្លាប់ចាស់ ហើយចាប់ផ្តើមនិយាយពីពាក្យដែលមានសុខភាព និងការចម្រុងចម្រើនជំនួសឱ្យការនេះដោយរបៀបណា?

៣. តើលោកអ្នកអាចបង្កើតការទំនាក់ទំនង ជាមួយនឹងព្រះវរបិតានៃអ្នកដែលគង់នៅស្ថានសួគ៌ ឱ្យបានស្និទ្ធស្នាលបន្ថែមទៀតដោយរបៀបណា?

# ការអធិស្ឋាន
# គឺជាការនាំយកស្ថានសួគ៌មកផែនដី

## *មេរៀនទី ២: ការអធិស្ឋានដែលមានជោគជ័យជាចាំបាច់*

ព្រះគម្ពីរសុភាសិត ១៥:២៩

ព្រះអម្ចាស់ទ្រង់គង់នៅឆ្ងាយពីភាពកំណាច ប៉ុន្តែ ទ្រង់ស្តាប់ឮនូវសេចក្តីអធិស្ឋានរបស់ពួកសុចរិត ។

### I. ជ័យជម្នះលើគបស័ត្រថាសាធារណៈ

មានមនុស្សជាច្រើនបានទទួលនូវការពិសោធន៍ ផ្សេងៗគ្នានៅក្នុងការចូលមកឯព្រះដោយអង់អាច នៅក្នុងសេចក្តីអធិស្ឋាននេះ គឺដោយសារតែមានអារម្មណ៍ថាខ្លួនមានភាពឥតតម្លៃ នៅជាប់មានទោស និងមានការផ្តន្ទាទោសនោះឯង ។ មានមនុស្សជាច្រើនក៏បានមានអារម្មណ៍ថា ព្រះទ្រង់មិនបានឆ្លើយនូវសេចក្តីអធិស្ឋានរបស់ពួកគេ គឺដោយសារតែពួកគេមានការដឹងខ្លួនថាបានធ្វើបាប ជំនួសឱ្យនូវការដឹងខ្លួនថាមានសេចក្តីសុចរិតនោះ ។ ប្រសិនបើសេចក្តីអធិស្ឋានរបស់យើងគឺត្រូវមានការខឹតខំប្រឹងប្រែង នោះយើងត្រូវតែមើលឃើញដោយខ្លួនយើងថា ព្រះទ្រង់បានមើលយើងឃើញដែរ ។ យើងត្រូវតែស្គាល់ពីអ្វី ដែលជាអត្ថន័យនៃការកើតជាថ្មី ។

### ក. ការបើកសម្តែងលើសេចក្តីសុចរិត

យើងត្រូវតែដឹងថា ឥឡូវនេះ យើងបានកើតជាថ្មីហើយព្រមទាំងបានបង្កើតមកឱ្យមានសេចក្តីសិចរិតទៀតផង ។ ព្រះទ្រង់មិនបានផ្តន្ទាទោសដល់យើងទេ ។ យើងបានកើតជាថ្មីខាងឯព្រះវិញ្ញាណហើយ ។ ព្រះគ្រីស្ទទ្រង់បានបង់ថ្លៃជំនួសអំពើបាបរបស់យើងហើយ ។ សេចក្តីសុចរិតរបស់ផងព្រះគ្រីស្ទ គឺបានដាក់មកលើយើងហើយ ។ ទ្រង់បានបញ្ចាពីគ្រប់ទាំងអារម្មណ៍ទាំងឡាយហើយ ។

ព្រះគម្ពីរ ២កូរិនថូស ៥:១៧

មនុស្សចាស់គឺមិនមាននៅក្នុងអ្នកណាទៀតឡើយ ។ គឺយើងបានកើតជាថ្មីខាងឯព្រះវិញ្ញាណហើយ ។ យើងកំពុងតែនិយាយអំពីមនុស្សខាងឯវិញ្ញាណ ។

ព្រះគម្ពីរ ២កូរិនថូស ៥:២១

នៅក្នុងការផ្លាស់ប្តូរដ៏អស្ចារ្យ ព្រះយេស៊ូវទ្រង់គឺជាអ្នកជំនួសរបស់យើង គឺជាអ្នកប្រោសលោះ ទ្រង់បានចាប់យកនូវអំពើបាបទាំងអស់របស់យើង ទៅដាក់នៅលើអង្គទ្រង់ ។ រីឯអំពើបាបរបស់យើងគឺត្រូវបានរើចេញហើយ សេចក្តីសុចរិតរបស់ផងព្រះយេស៊ូវគ្រីស្ទ គឺបានដាក់ចូលមកក្នុងយើងហើយ។ ពីដើមមកយើងមិនបានទទួលនូវសេចក្តីសុចរិតឡើយ គឺទើបតែយើងបានត្រឡប់មកជាបានទទួល នូវសេចក្តីសង្គ្រោះក្នុងមួយរំពេចនោះតែប៉ុណ្ណោះ ។

### ខ.យើងរាល់គ្នាបានទទួលនូវការអត់ទោស និងការសម្អាត

មានអ្នកជឿជាច្រើនក៏បានមានអារម្មណ៍ថា លែងមានការជិតស្និទ្ធមកពីព្រះ ពីព្រោះអំពើបាបដែលគេបានធ្វើតាំងតែពីពួកគេបានកើតមកម៉្លេះ ។ ចូរសារភាពអំពើបាបទាំងនោះទៅព្រះ នោះទ្រង់នឹងអត់ទោស និងសម្អាតពីគ្រប់ទាំងអំពើទុច្ចរិតទាំងអស់នោះ ។ សេចក្តីសុចរិតរបស់យើងក៏ផ្តើមមាននៅក្នុងព្រះអង្គ គឺជាការកែជាថ្មីនោះឯង ។

ព្រះគម្ពីរ ១យ៉ូហាន ១:៩

ចំពោះការបើកសម្តែងពីសេចក្តីសុចរិត នោះយើងអាចចូលមកដោយក្លាហានចំពោះព្រះវរបិតានៃយើង ដែលគង់នៅ

ស្ថានសួគ៌ ក្នុងសេចក្តីអធិស្ឋាន គឺដោយគ្មានអារម្មណ៍ថា ជាប់មានទោស និងនៅជាប់មានការផ្តន្ទាទោស ដែលយើងធ្លាប់បានលាក់ទុកនៅក្នុងសេចក្តីអធិស្ឋានរបស់យើង ពីអតីតកាលនោះហើយ ។ យើងអាចដឹងថា ព្រះទ្រង់ស្រឡាញ់យើងព្រមទាំងញញឹមមកកាន់យើងជានិច្ច ។ អំពើបាបរបស់យើងឥឡូវនេះ ដែលនៅក្រោមព្រះលោហិតរបស់ព្រះយេស៊ូវ នោះគឺត្រូវបានអត់ទោស ត្រូវបានសម្អាត និងបានរាប់ជាសុចរិតហើយ ។ ចូរធ្វើការព្រមព្រៀងជាមួយនឹងព្រះចុះ ។ យើងគឺជាអ្នកដែលគ្មានទោស ឬក៏គ្មានការផ្តន្ទាទោសទៀតទេ ។

ព្រះគម្ពីរហេព្រើរ ១០:១៧-២២

ចំពោះការបើកសម្តែងពីសេចក្តីសុចរិត នោះយើងអាចចូលមកដោយក្លាហាន ចំពោះព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ ក្នុងសេចក្តីអធិស្ឋានហើយ ។

### គ. យើងបានទទួលការជ្រើសរើសហើយ

ព្រះគម្ពីរសេផានា៣:១៧

ព្រះគម្ពីរ ១ពេត្រុស ២:៩

ព្រះគម្ពីរអេភេសូរ ៣:១២

ព្រះគម្ពីរហេព្រើរ ៤:១៦

ពិតមែនហើយ ព្រះវរបិតាទ្រង់បានស្តាប់ឮនូវសេចក្តីអធិស្ឋានរបស់ពួកសុចរិត ។ ទ្រង់បានជ្រើសរើសយើងរាល់គ្នាជាមនុស្សពិសេសរបស់ព្រះអង្គទ្រង់ផ្ទាល់ហើយ ឱ្យមានភាពជាស្តេច ជាសង្ឃនោះឯង ។ ព្រះទ្រង់បានជ្រើសរើសយើងឱ្យបានធ្វើជាស្តេច ជាសង្ឃ ។ យើងបានធ្វើសង្ឃហ្លួងហើយ គឺយើងអាចអធិស្ឋានជាសេចក្តីអធិស្ឋាន ដ៏មានភាពជឿនលឿនខាងឯនគរព្រះ គឺដែលយើងស្គាល់យ៉ាងប្រចក្សច្បាស់ ដោយការអធិស្ឋានដ៏ភ្លៀវក្លានៃមនុស្សសុចរិត ដែលអាចរកបានដ៏ច្រើនលើសលុបនោះឯង ។ យើងមិនត្រូវជាអ្នកលុតក្រាប ឬក៏ជាអ្នកសុំអង្វរកនោះទេ ។ យើងគឺជាអ្នកដាស់តឿនក្រើនរំឭកវិញ ដើម្បីឱ្យបានចូលមកដោយក្លាហាននៅចំពោះបល្ល័ង្កនៃព្រះគុណដ៏ពិតប្រាកដ ។

## II. ការទិតទំអធិស្ឋានគឺជាការចាំបាច់

### ក.ការមានលំនៅនៅក្នុងទ្រង់

ព្រះគម្ពីរអេភេសូរ ២:១៣

ព្រះគម្ពីរទំនុកដំកើង ៩១:១

ពេលដែលយើង "មានលំនៅ" នៅក្នុងការទំនាក់ទំនងដ៏ស្និទ្ធស្នាលជាមួយនឹងព្រះអង្គ នោះការសម្រេចចិត្តដែលអស់ពីដួងចិត្តរបស់យើង នឹងបានត្រឡប់មកជាម្នាក់ដែលមានការស្រឡាញ់ងប់ទៅនឹងបុគ្គលិកលក្ខណៈ នៃព្រះវរបិតារបស់យើង ។ ការសម្រេចព្រះទ័យរបស់ទ្រង់នឹងបានត្រឡប់មកជាការសម្រេចចិត្តរបស់យើង ។ ព្រះទ្រង់មិនឃ្លាតឆ្ងាយពីយើងទេ ។ យើងមានទំនាក់ទំនងជាមួយនឹងព្រះអង្គ ។ យើងបានត្រឡប់មកជាតែមួយជាមួយនឹងទ្រង់ ។ យើងបានត្រឡប់មកជាមិត្តភក្តិរបស់ទ្រង់ ។ ព្រះបន្ទូលរបស់ទ្រង់ត្រូវតែតាំងលំនៅនៅក្នុងយើង ។ យើងបានជញ្ជឹងគិតពីព្រះបន្ទូលរបស់ទ្រង់ទាំងថ្ងៃទាំងយប់ នោះការសម្រេចព្រះទ័យរបស់ទ្រង់បានត្រឡប់មកជាការសម្រេចចិត្តរបស់យើង ។

ព្រះគម្ពីរយ៉ូហាន ១៥:៧

នោះគឺជាការអធិស្ឋានលើគ្រប់ទាំងអស់ ។ ការសម្រេចចិត្តរបស់យើង គឺបានត្រឡប់មកជាកាសម្រេចព្រះទ័យរបស់ទ្រង់ ។ បំណងចិត្តរបស់យើងបានត្រឡប់ទៅជាបំណង

ព្រះហឫទ័យរបស់ទ្រង់ យើងបានត្រឡប់ទៅជាតែមួយជាមួយនឹងទ្រង់ ។ សេចក្ដីអធិស្ឋានរបស់យើង គឺបានត្រឡប់ទៅជាការខឹតខំប្រឹងប្រែងកាន់តែរីកធំទៅៗ ។ យើងបានជញ្ជឹងគិតពិចារណាពីព្រះបន្ទូលរបស់ទ្រង់ រហូតដល់ព្រះបន្ទូលនៃទ្រង់បានត្រឡប់ទៅជាពេញបរិបូរណ៍ នៅក្នុងយើង។

ព្រះគម្ពីរទំនុកដំកើង ៣៧:៤-៥

## ខ. ទូលសូមទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់

ព្រះគម្ពីរ ១យ៉ូហាន ៥:១៤-១៥

ខ្ញុំបានប្រើពាក្យនេះដើម្បីទូលប្រាប់ដល់ព្រះ ពីអ្វីដែលខ្ញុំចង់បាន និងពីអ្វីដែលខ្ញុំបានគិត បានត្រូវការនោះ ។ ខ្ញុំទូលសូមថា បំណងចិត្តរបស់ខ្ញុំបានសម្រេចហើយ ។ តើលោកអ្នក បានបញ្ជាក់នៅក្នុងព្រះហើយឬនៅ? សេចក្ដីសន្យារបស់ព្រះ គឺតាំងមូលដ្ឋានលើបុគ្គលិកលក្ខណៈរបស់ទ្រង់ និងលើទម្លាប់របស់ទ្រង់ក្នុងការឆ្លើយតប ។ ប្រសិនបើយើងទូលសូមទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ នោះទ្រង់នឹងស្ដាប់ឮយើងហើយ ។ តើលោកអ្នកស្គាល់ពីបំណងព្រះហឫទ័យរបស់ទ្រង់ឬទេ? តើលោកអ្នកទូលសូមដោយយោលទៅតាមបំណងហើយឬនៅ? ប្រសិនបើយើងដឹងថា ទ្រង់ស្ដាប់ឮយើងហើយនោះ អញ្ចឹងយើងនឹងដឹងថា ទ្រងនឹងឆ្លើយនូវសេចក្ដីអធិស្ឋានរបស់យើងហើយ ។

ព្រះគម្ពីរយ៉ាកុប ៤:៣

តើលោកអ្នកបានទូលសូម ហើយគ្មានចម្លើយឬទេ? តើខ្ញុំបានទូលសូមសម្រាប់តែខ្ញុំខ្លួនឯង ហើយបានគាប់តែចិត្តរបស់ខ្ញុំឬទេ? គ្រប់យ៉ាងគឺអំពីនគររបស់ព្រះអង្គ បំណងព្រះហឫទ័យរបស់ទ្រង់គឺនឹត្រូវបានសម្រេច ។

## គ. ទីមួយគឺជាការថ្វាយបង្គំ

ព្រះគម្ពីរម៉ាថាយ ៦:៣៣

ទីមួយ យើងត្រូវតែថ្វាយបង្គំព្រះអង្គ និងស្វែងរកព្រះភក្ត្រទ្រង់ ។ ការទំនាក់ទំនងគឺតម្រូវឱ្យមានការនិយាយ និងការស្ដាប់ សម្រាប់មនុស្សពីរ ឬបីនាក់ ។ កុំគិតតែពីការជជែកគ្រប់រឿងនោះឡើយ ។ ចូរឈប់និយាយ ហើយចំណាយពេលស្ដាប់ពីការទទួលខុសត្រូវរបស់ព្រះ ឱ្យតបឆ្លើយមកលោកអ្នក ហើយឱ្យបានស្ដាប់ឮព្រះអង្គវិញផង ។ តើព្រះមានជំនាញជាងលោកអ្នកឬ?ចូរស្ដាប់ព្រះអង្គ និងរៀនពីបំណងព្រះហឫទ័យរបស់ទ្រង់ផង ។ បន្ទាប់មក ចូរនិយាយថា "សូមឱ្យបំណងព្រះហឫទ័យបានសម្រេចនៅផែនដី ដូចជានៅស្ថានសួគ៌ដែរ" ។

## ឃ.តើខ្ញុំស្គាល់បំណងព្រះហឫទ័យព្រះដោយវិធីណា?

ព្រះគម្ពីរយ៉ាកុប ១:៥

កំណត់ចំណាំៈ សេចក្ដីអធិស្ឋានគឺត្រូវតែជាការសន្ទនាជាមួយនឹងព្រះ ។ យើងទូលសូមសម្រាប់ចំណេះដឹងពីបំណងព្រះហឫទ័យរបស់ទ្រង់ នោះត្រូវស្ដាប់ឱ្យបានទទួលចំណេះដឹងមកពីទ្រង់ ហើយបន្ទាប់មក ចូរអធិស្ឋានថា ត្រូវតែ "និយាយ" សម្រាប់បំណងព្រះហឫទ័យរបស់ទ្រង់ ឱ្យបានសម្រាប់នៅផែនដី ដូចជាបានបើកសម្ដែងចំពោះលោកអ្នកមកពីស្ថានសួគ៌ដែរ ។ ប្រសិនបើព្រះទ្រង់មានជំនាញជាងខ្ញុំ ហេតុអ្វីបានជាខ្ញុំធ្វើការនិយាយគ្រប់យ៉ាងទាំងអស់? យើងត្រូវការការបើកសម្ដែងមកពីព្រះ ដូច្នេះ យើងត្រូវតែស្ដាប់ពីព្រះអង្គផ្ទាល់ ។

ព្រះគម្ពីរលូកា ១១:២៥

## III. គំរូពីព្រះគម្ពីរសញ្ញាចាស់

### ក. សេចក្តីអធិស្ឋានរបស់ស្តេចដាវីឌ

ស្តេចដាវីឌបានទទួលនូវការបើកសម្តែង ពីបំណងព្រះហឫទ័យរបស់ព្រះ ហើយបន្ទាប់មកក៏បានអធិស្ឋានសម្រាប់ការនោះនៅលើផែនដី ដូចជាព្រះទ្រង់បានបើកសម្តែងពីការនោះមកពីស្ថានសួគ៌ដែរ ។

ព្រះគម្ពីរ ២សាំយូអែល ៧:២៦-២៩

ក្នុងមួយរំពេចបន្ទាប់ពីការនេះ ការឆ្លងនៅតែបន្តធ្វើរបាយការណ៍ពីរបៀបដែលស្តេចដាវីឌបានចុះចាញ់ចំពោះខ្មាំងសត្រូវរបស់ទ្រង់ទាំងអស់របស់ទ្រង់ ។ ស្តេចដាវីឌបានឮមកពីព្រះ ។ (នោះគឺជាការស្តាប់នូវសេចក្តីអធិស្ឋាន) ។ ស្តេចដាវីឌបានអធិស្ឋានពីអ្វីដែលទ្រង់បានឮព្រះទ្រង់មានបន្ទូល ។ ពេលដែលស្តេចដាវីឌបានមានបន្ទូល
ពីការអធិស្ឋាននោះក៏បានត្រឡប់មកជាពិតប្រាកដ ។

### ខ. សេចក្តីអធិស្ឋានរបស់ហោរាអេលីសេ

នៅពេលដែលប្រឈមមុខនឹងសេចក្តីស្លាប់របស់កូន នោះអេលីសេក៏បានអធិស្ឋានសម្រាប់ការបើកសម្តែង ពីបំណងព្រះហឫទ័យរបស់ព្រះ អេលីសេក៏បានធ្វើចលនាផ្លាស់ប្តូរ និងបាននាំមកនូវជីវិតចូលទៅក្នុងរូបកាយរបស់កូននោះ ។

ព្រះគម្ពីរ ២ពង្សាវតារក្សត្រ ៤:៣២-៣៥

យើងត្រូវការចំណាយពេលជាមួយនឹងព្រះអម្ចាស់ និងថ្វាយបង្គំដល់ទ្រង់រហូតដល់យើងបានទទួល មកពីព្រះផ្ទាល់ ហើយអធិស្ឋានតាមលំដាប់លំដោយទៅ ។ ដើម្បីអធិស្ឋានដោយមានការខឹតខំប្រឹងប្រែង នោះយើងត្រូវតែចំណាយពេលវេលាជាមួយនឹងព្រះវរបិតានៃយើង ព្រមទាំងស្តាប់នូវការបើកសម្តែងមកពីទ្រង់ ។ បន្ទាប់មក យើងនិយាយពីអ្វីដែលព្រះទ្រង់បានបង្ហាញឱ្យយើងនិយាយ ។

## IV. កម្លាំងធម្មជាតិនៃសេចក្តីអធិស្ឋាន

### ក. អធិស្ឋានដោយសេចក្តីពិត

ព្រះគម្ពីរទំនុកដំកើង ១៤៥:១៨

នៅពេលដែលយើងអធិស្ឋាន នោះយើងត្រូវតែបានបើកចំហចិត្តដោយតៀងត្រង់ជាមួយនឹងព្រះ ។ ពាក្យជាភាសាហេព្រើរ សម្រាប់សេចក្តីពិតនេះ ក៏នាំមកនូវអត្ថន័យនៃពាក្យស្ថិតស្ថេរ និងភាពគួរឱ្យទុកចិត្ត ។ ចូរអធិស្ឋានតាមព្រះបន្ទូលព្រះ នោះនឹងគ្មានបញ្ហាឡើយ ។ ជំនួសឱ្យនូវការអធិស្ឋានដោយយកចិត្តទុកដាក់របស់យើង នោះការសង្ស័យ ឬក៏ការភ័យខ្លាចរបស់យើង ឬក៏សូម្បីតែ "សេចក្តីពិត" ខាងផ្នែកធម្មជាតិ ដែលយើងត្រូវតែអធិស្ឋាន ដោយនូវ "សេចក្តីពិត" ដែលមកពីព្រះបន្ទូលរបស់ព្រះនោះក៏ដោយ ។ ពេលដែលយើងទំនាក់ទំនងជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងសេចក្តីអធិស្ឋាន នោះទ្រង់នឹងបើកសម្តែងពី "សេចក្តីពិត" មកកាន់យើង គឺដែលទ្រង់បានស្តាប់ឮការអធិស្ឋាននោះ ពីព្រះវរបិតាមកដែរ ។

ព្រះគម្ពីរយ៉ូហាន ១៦:១៣

នៅពេលដែលសេចក្តីពិត បានបើកសម្តែងមកដល់យើងដោយព្រះវិញ្ញាណបរិសុទ្ធ នោះយើងត្រូវតែ "និយាយ" នៅក្នុងសេចក្តីអធិស្ឋានថា នាំយកបំណងព្រះហឫទ័យរបស់ព្រះមកឱ្យបានសម្រេចនៅលើផែនដី ដូចជាវាបានបើកសម្តែងមកពីស្ថានសួគ៌ដែរ ។ នៅពេលដែលយើងស្តាប់ឮសេចក្តីពិតចេញពីព្រះ ហើយនិយាយនៅក្នុងសេចក្តីអធិស្ឋានថា វានឹងនាំមក

នូវបំណងព្រះហឫទ័យរបស់ព្រះ ឱ្យបានឆ្លងកាត់ផែនដី ដូចជាបានឆ្លងកាត់នៅស្ថានសួគ៌ដែរ ។

## ខ. ការអធិស្ឋានយ៉ាងក្លៀវក្លា

ព្រះគម្ពីរយ៉ាកុប ៥:១៦ខ

សេចក្តីអធិស្ឋានរបស់យើង គឺត្រូវតែបានជាការអធិស្ឋានយ៉ាងក្លៀវក្លា មានប្រពលភាពនិងឆ្លងកាត់ដូចជាអណ្តាតភ្លើង ដែលមានភ្លើងនៃព្រះវិញ្ញាណបរិសុទ្ធ ។

ព្រះគម្ពីរកូល៉ុស ៤:១២

ព្រះគម្ពីរវិវរណៈ ៣:១៤-១៦

នៅពេលដែលព្រះទ្រង់បានបើកសម្តែង ពីបំណងព្រះហឫទ័យរបស់ទ្រង់មកដល់យើង នោះយើងត្រូវតែអនុវត្តវាដោយមាន "ការខឹតខំប្រឹងប្រែង មានសេចក្តីអធិស្ឋានដ៏ក្លៀវក្លា" ។ ពេលដែលព្រះទ្រង់បានប្រទានពរដល់ពួកកូនចៅអ៊ីស្រាអែលនូវទឹកដីសន្យា នោះពួកគេបានរកឃើញថា ខ្មាំងសត្រូវនោះគឺ "កំពុងតែបោះទ័ព" ប្រុងប្រៀបជាស្រេច ។ នៅពេលដែលព្រះទ្រង់បានបើកសម្តែង ពីបំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់រឿងរ៉ាវទាំងឡាយ ដែលទ្រង់សព្វព្រះហឫទ័យចង់ឱ្យយើង "កាន់កាប់" ក្នុងការអធិស្ឋាន នោះយើងតែងតែរកឃើញនូវ "ខ្មាំងសត្រូវ" កំពុងតែបោះទ័ពនៅទីនោះ ។ យើងត្រូវតែចូលទៅកាន់កាប់នូវកម្មសិទ្ធិរបស់យើង ដោយចិត្តក្លៀវក្លាក្នុងសេចក្តីអធិស្ឋាន ដែលមានសិទ្ធិអំណាច និងអំណាចគ្រប់គ្រងនោះ ។ យើងត្រូវតែបង្កើនទៅមុខនូវកងកម្លាំងនគររបស់ព្រះតាមអ្វីដែលយើង "និយាយ" នៅពេលដែលយើងអធិស្ឋាននោះ ។ ខ្មាំងសត្រូវកំពុងតែបោះទ័ពនៅលើទឹកដីរបស់យើង ។ យើងត្រូវការបង្កើនទៅមុខនូវកងកម្លាំងនគររបស់ព្រះ ។

## គ. ការខឹតខំប្រឹងប្រែងយ៉ាងខ្លាំង

ព្រះគម្ពីររ៉ូម ១៥:៣០

"ការខឹតខំប្រឹងប្រែងយ៉ាងខ្លាំង" មានន័យថា ខំប្រឹងហ្មឹកហ្មឺនដ៏ច្រើនលើសលុប ដោយសេចក្តីស្វហាប់ ឬក៏ដោយសេចក្តីព្យាយាម ក្នុងការបម្រាសនទៀល ឬប្រយុទ្ធប្រឆាំងដោយប្រើអាណាចក្នុងការវាយប្រហារនោះ ។ រីឯលោកសាវ័កប៉ុលវិញ ក៏បាននៅក្នុងសមរភូមិ ហើយគាត់ក៏បានសុំឱ្យពួកអ្នកជឿ ខឹតខំប្រឹងតស៊ូជាមួយនឹងគាត់ក្នុងការអធិស្ឋានដើម្បីដណ្តើមយកជ័យជម្នះ ។ ចូរសង្ឃឹមឡើង ខ្មាំងសត្រូវវាបានទប់ទល់ រហូតទាល់តែត្រូវវិនាសខ្លួន ជ័យជម្នះគឺត្រូវបានប្រទានមកឱ្យយើងហើយ ។

## ឃ.ការសុំ ការគោះ និងការស្វែងរក

ព្រះគម្ពីរម៉ាថាយ ៧:៧-៨

ព្រះទ្រង់បានមានបន្ទូលពីការនេះ ។ ព្រះទ្រង់បានបើកសម្តែងពីការនេះដល់យើង ។ ឥឡូវនេះយើងត្រូវធ្វើការស្វែងរកនោះនឹងឃើញ ។

ព្រះគម្ពីរចោទិយកថា ៤:២៩

ព្រះទ្រង់សព្វព្រះហឫទ័យចង់ឱ្យយើង ស្វែងរកព្រះអង្គឱ្យការទាំងនោះបានកើតមានឡើង និងមានការប្តេជ្ញាចិត្តទាំងស្រុងនោះឯង ។

ព្រះគម្ពីរយេរេមា ២៩:១២-១៣

យើងត្រូវការស្វែងរកព្រះ ដោយអស់ពីចិត្ត ។ គឺមិនត្រូវធ្វើការអធិស្ឋានត្រឹមតែពាក់កណ្តាល តទៅទៀតឡើយ ។ ចូរធ្វើការចាប់យកនូវពេលវេលាក្នុងការស្តាប់ និងទទួលខុសត្រូវជាលំដាប់លំដោយ ។

## ង. ការខំប្រឹងខ្លាំង

ព្រះគម្ពីរកាឡាទី ៤:១៩

ពាក្យ "ការខំប្រឹងខ្លាំង" គឺត្រូវបានប្រើនៅក្នុងព្រះគម្ពីរឃិងជេម ដែលមានន័យប្រហាក់ប្រហែលនឹងពាក្យ "កម្មករ" ដែលម្ដាយបានផ្ដល់កំណើតឱ្យធ្វើជាកូន ។ លោកសាវ័កប៉ុលក៏មានឪពុកខាងឯវិញ្ញាណជាច្រើន ព្រមទាំងបានទទួលការប្រឹក្សាពីពួកគេជាកូនរបស់គាត់ នៅក្នុងព្រះអម្ចាស់ ។ នេះគឺមិនមែនជាការអធិស្ឋានជាធម្មតាៗនោះទេ គឺជាការផ្ចង់ចិត្តជាបន្តឱ្យបានបំពេញតាមគោលបំណង ដែលត្រូវបានប្រទានពរមកឱ្យនោះ ។

នៅពេលដែលយើងបានអធិស្ឋានយ៉ាងភ្លៀវក្លា និងអស់ពីកម្លាំងកាយចិត្ត នោះយើងត្រូវតែមានការប្រុងប្រយ័ត្ន គឺមិនត្រូវឱ្យការអធិស្ឋាននោះបានត្រឡប់ទៅជា "ប្រព័ន្ធនៃការងារ" ឡើយ ។ មានអ្នកខ្លះបានបង្កើតជាគោលលទ្ធិគឺធ្វើឱ្យទៅជា "ការខំប្រឹងខ្លាំង" នេះរហូតដល់បានត្រឡប់មកជាតុល្យភាពជាមួយនឹងការខឹតខំប្រឹងរបស់មនុស្សទៅវិញ ។ យើងត្រូវតែទទួលដោយនូវការអធិស្ឋាន ជាមូលដ្ឋានលើការងាររបស់ព្រះគ្រីស្ទដ៏ពេញលេញវិញ ។

ហោរាអេសាយបានទាយពីការងារយាងមក របស់ព្រះគ្រីស្ទធ្វើជាយញ្ញបូជាជំនួសយើង:

ព្រះគម្ពីរអេសាយ ៥៣:៨-៥៤:១

ព្រះវរបិតាទ្រង់បានទតឃើញ នូវការខំប្រឹងខ្លាំង ដែលបានបង្កើតដោយព្រះយេស៊ូវ ដ៏ជាអ្នកជមទួស ជាអ្នកប្រោសលោះដល់យើង ហើយទ្រង់ក៏បានចំម្អែតដល់យើង ។ ព្រះយេស៊ូវទ្រង់បានបង្កើតការទូលសូមអង្វរជំនួសយើង គឺជា (អ្នកប្រព្រឹត្តរំលង) ជំនួសយើងវិញ ។ ដោយសារតែការងាររបស់ព្រះគ្រីស្ទដ៏ពេញលេញ មកជាប្រយោជន៍របស់យើងនោះ គឺសម្រាប់អស់អ្នកណាដែលមិនទានមាន "ការខំប្រឹងខ្លាំង" នោះនឹងត្រូវបានបំបាក់បំបែកចេញ ឱ្យបានចូលទៅក្នុងការច្រៀងនោះ ។ ការងាររបសខ្ញុំទ្រង់នោះគឺបានពេញលេញវិញហើយ ។

ពិតមែនហើយ យើងត្រូវបានជាកម្មករ ឬ "ជាអ្នកធ្វើការ" ដោយមានប្រពលភាព និងមានសេចក្ដីភ្លៀវក្លាក្នុងការអធិស្ឋាននោះ ប៉ុន្តែ នៅពេលដដែលនោះ ចូរចងចាំថា យើងគ្រប់គ្នាត្រូវតែទទួលមូលដ្ឋានគ្រឹះ លើការងាររបស់ព្រះគ្រីស្ទដ៏ពេញលេញនោះឯង គឺមិនមែនការខឹតខំប្រឹងប្រែងដោយខ្លួនយើងផ្ទាល់នោះទេ ។ យើងមិនត្រូវមានការជឿជាក់លើព្រះតែខ្ទាំងសត្រូវក៏វាអាចត្រូវបានធ្វើការបោះទ័ព នៅទីងទីតាំងរបស់យើងដែរ ដូច្នេះ ក៏មានប្រពលភាពនៃការកាន់កាប់ដែលជាកម្មសិទ្ធិរបស់យើងនៅក្នុងសេចក្ដីអធិស្ឋាននោះដែរ ។

## ច. អធិស្ឋានដោយមិនឈប់ឈរ

ព្រះគម្ពីរ ១ថែស្សាឡូនិច ៥:១៧

យើងត្រូវតែអភិវឌ្ឍនូវជីវិតនៃសេចក្ដីអធិស្ឋាន ជាប្រចាំថ្ងៃ ហើយនិងធ្វើការទំនាក់ទំនងឱ្យខ្ជាប់ខ្ជួន ជាមួយនឹងព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ ។ ពេលដែលយើងបានអធិស្ឋានដោយវិញ្ញាណ គឺសូម្បីតែនៅពេលដែលយើងកំពុងដេក ឬកំពុងជាប់រវល់ជាមួយនឹងការធ្វើការផ្សេងៗក៏ដោយ ក៏វិញ្ញាណរបស់យើងនឹងនៅតែបន្តការអធិស្ឋាន ដោយគ្មានការឈប់ឈរដែរ ។ យើងពេញចិត្តនឹងការទាំងនោះ នៅក្នុងព្រះគម្ពីរកិច្ចការ នោះត្រូវតែបានជា "ការខ្ជាប់ខ្ជួន" នៅក្នុងការអធិស្ឋានរបស់យើងនោះឯង ។ ព្រះគម្ពីរកិច្ចការ ១២:៥ ។

## ឆ. ការស្តាប់សេចក្តីអធិស្ឋាន

នៅពេលដែលយើងយល់ពី "ការចាំបាច់" ការខឹតខំប្រឹងប្រែងអធិស្ឋាន នោះយើងនឹងរកឃើញដោយខ្លួនឯងនូវការចំណាយពេលបន្ថែមទៀតនៅក្នុង "ការស្តាប់សេចក្តីអធិស្ឋាន" (គឺជាការស្ថិតនៅក្នុងតំបន់ខាងឯវិញ្ញាណ នៅនគរស្ថានសួគ៌ គឺជាការនៅតែបន្តនូវការស្តាប់ឮសម្លេងទូចឆ្មាររបស់ព្រះ និងការស្គាល់ពីអ្វីដែលទ្រង់នឹងសព្វព្រះហឫទ័យនោះ) ហើយបន្ទាប់មក ក៏និយាយដោយអង់អាចពីអ្វីដែលយើងបានស្តាប់ឮព្រះវរបិតាទ្រង់មានបន្ទូលនោះ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលៈ

ព្រះគម្ពីរយ៉ូហាន ៥:១៩

ព្រះគម្ពីរយ៉ូហាន ១៤:១០

ការដើរតាមគំរូរបស់ព្រះយេស៊ូវ នោះយើងបានត្រឹមតែនិយាយនៅក្នុងសេចក្តីអធិស្ឋានពីអ្វី ដែលយើងបានស្តាប់ឮជាដំបូងពីព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌នោះឯង ។ ដោយមានរឿងរ៉ាវទាំងនោះហើយ ដែលយើងនិយាយក្នុងពេលអធិស្ឋានតាមបំណងព្រះហឫទ័យព្រះ នោះយើងកំពុងតែបានបង្កើតជាមួយនឹងផលផ្លែ នៃបបូរមាត់របស់យើងនោះឯង ។ បើយើងនៅបន្តការសន្យា និងបន្តការអធិស្ឋានដ៏ខ្ជាប់ខ្ជួននោះ យើងនឹងមានការឱ្យដំបូន្មានដ៏ខ្លាំងក្លាពីនគររបស់ព្រះនៅលើផែនដីនេះហើយ ។ ជីវិតដែលមានការឆ្លងកាត់ដោយភ្លើងរបស់ព្រះគ្រីស្ទ នោះយើងនឹងនាំមកនូវនគររបស់ព្រះចុះមកសម្រេចនៅលើផែនដី ដូចជានៅស្ថានសួគ៌ដែរ ។

## ក្រុមពិភាក្សា

១. ចូរពិភាក្សាពីអ្វីដែលមានន័យថា ការកើតជាថ្មី ។

២. តើយើងយល់ព្រមជាមួយនឹងព្រះក្នុងការអធិស្ឋាន ដោយវិធីណា?

៣. ចូរចែកចាយពីលទ្ធផលនៃសមត្ថភាពខ្លះ ដែលទូលសូមទៅដោយគ្មានចម្លើយចូលមកតាមរយៈ យ៉ាកុប ៤:៣ ។

## ការសិក្សាដោយខ្លួនឯង

១. តើមានអំពើបាបណាមួយ ដែលចេញមកពីអតីតកាលរបស់លោកអ្នក ដែលទុកឱ្យលោកអ្នកមានអារម្មណ៍ថាលែង មានការជិតស្និទ្ធមកពីព្រះនោះ?

   ក. ប្រសិនបើដូច្នោះមែន តើបាបអ្វីខ្លះទៅ? ចូរសារភាពនូវអំពើបាបទាំងនោះ ត្បិតព្រះទ្រង់សុចរិតនៅពេលឥឡូវនេះ ហើយនៅតំបន់ដែលលោកអ្នកបានទទួលនូវការអត់ទោស និងការសម្អាតពីគ្រប់អំពើទុច្ចរិតទាំងអស់នោះផង (១យ៉ូហាន ១:៩) ។

   ខ. ប្រសិនបើមិនមានទេ ចូរសរសើរដល់ព្រះអម្ចាស់ចំពោះការអត់ទោសរបស់ទ្រង់ ដែលទ្រង់បានបំផ្លាស់បំប្រែជីវិតរបស់យើង ។

២. ចូរសរសេរចុះនូវផ្លូវខ្លះៗ ដែលលោកអ្នកអាចបញ្ជាក់ថាលោកអ្នកបានចូកមកឯបល្ល័ង្ក នៃព្រះគុណរបស់ព្រះវរបិតានៃលោកអ្នក ដែលគង់នៅស្ថានសួគ៌ដោយអង់អាចកំឡុងពេលអធិស្ឋាន ជំនួសឱ្យនូវការលុតក្រាប និង/ឬការទទួលទោសនោះ ។

៣. ចូរឱ្យពង់ចំពោះការអនុវត្តន៏ "ការស្តាប់" កំឡុងពេលនៃសេចក្តីអធិស្ឋានរបស់លោកអ្នក ក្នុងថ្ងៃនីមួយៗនោះ ។

ចូរធ្វើឱ្យបានខ្ជាប់ខ្ជួន នូវដំណើរដែលលោកអ្នកបានសរសេរចុះនូវអ្វី ដែលព្រះទ្រង់បានមានបន្ទូលមកកាន់លោកអ្នកនោះ ។

# ការអធិស្ឋាន
# គឺជាការនាំយកស្ថានសួគ៌មកផែនដី
### *មេរៀនទី ៣: ការអធិស្ឋានឱ្យនគរបានជឿនទៅមុខ*

## I. សិទ្ធិអំណាចគឺជាគ្រឹះចាំនៃការអធិស្ឋាន

ចំពោះការយល់ដឹងដ៏ល្អិតល្អន់រចត់ ពីរបៀបអធិស្ឋានឱ្យការអធិស្ឋានឱ្យនគរបានជឿនទៅមុខ នោះខ្ញុំនឹងចាប់ផ្ដើមនូវការផ្ដល់ឱ្យពីរំឭកនូវការបង្រៀនរបស់យើង ទៅលើ "សិទ្ធិអំណាចរបស់អ្នកជឿ" ។

### ក. ដើមកំណើតនៃវិញ្ញាណអាក្រក់

នៅពេលដែលលូស៊ីហ្វើរ និងពួកទេវតារបស់វាទាំងអស់ដែលនៅក្រោមការបញ្ជារបស់វានោះ ក៏បានបះបោរប្រឆាំងជាមួយនឹងព្រះ គឺពួកគេបានត្រូវបណ្ដេញចេញពីស្ថានសួគ៌ ឱ្យចុះមកភពមួយទៀត ដែលហៅថាភពផែនដី ។ នៅក្នុងការបះបោររបស់វានេះ លូស៊ីហ្វើរបានមានបំណងដោយខ្លួនវាផ្ទាល់ថា "ឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត" ហើយនិងបានគ្រប់គ្រងលើស្ថានសួគ៌ និងចក្រវាឡទាំងមូល ។ ជំនួសឱ្យនូវការនេះ ឥឡូវនេះគេបានដឹងថា ជាពស់ពីបុរាណ គឺជាអារក្ស ។ វា និងពពួកវិញ្ញាណអាក្រក់របស់វា គឺត្រូវបានទទួលនូវអន្ទាក់នៅលើភពមួយដែលងងឹត គឺដែលគ្មានទម្រង់នៅទទេ ។

ព្រះគម្ពីរលោកុប្បត្តិ ១:២

### ខ. ការកែផែនដីជាថ្មីឡើងវិញ

ប៉ុន្តែ ក្នុងមួយរំពេចភ្លាមនោះ វាបានឮសម្លេងរបស់ព្រះមានបន្ទូលថា "ចូរឱ្យមានពន្លឺឡើង!" សេចក្ដីរន្ធត់របស់អារក្សគឺកំឡុងពេល៥ថ្ងៃនៅលើផែនដីនេះ គឺត្រូវបានទទួលនូវការកែជាថ្មីឡើងវិញ នូវគោលបំណងនៃការបង្កើតជាដំបូងរបស់វា ដោយព្រះដ៏ជាអ្នកបង្កើតនោះ ។ ហើយព្រះទ្រង់មានបន្ទូលថា "គឺជាការល្អ" ។

### គ. ការបង្កើតមនុស្ស

ព្រះទ្រង់មានផែនការ គឺដែលទ្រង់មានបន្ទូលថា: "ចូរយើងបង្កើតមនុស្សឱ្យដូចជារូបយើង" ។ នៅថ្ងៃទី៦នោះសាតាំងដែលចង់ធ្វើខ្លួនវា "ឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត" នោះ វាបានចាំឃ្លាំមើលដោយសេចក្ដីរន្ធត់ នៅពេលដែលព្រះដ៏ជាអ្នកបង្កើត គឺជាព្រះរាជបុត្រារបស់ព្រះ គឺដែលទ្រង់សូនមកពីធូលីដីបង្កើតជាមនុស្សប្រុសស្រីឡើង ឱ្យមានរូបភាពដូចជាព្រះអង្គនោះ គឺឱ្យមានភាពដូចជាព្រះអង្គសុទ្ធសាធនៅលើផែនដីនេះ ។ ទ្រង់បានផ្លុំខ្យល់ជីវិតរបស់ព្រះអង្គបញ្ចូលទៅឱ្យលោកអ័ដាម ។ ក្នុងមួយរំពេចនោះឯង ទ្រង់ក៏បានបង្កើតនាងអេវ៉ា ក៏នាំនាងទៅឯលោកអ័ដាម និងប្រាប់ពួកគេថា ចូរបង្កើតកូនឱ្យបានចម្រើនជាច្រើនឡើង នៅលើផែនដីឱ្យមានភាពដូចជាព្រះទាំងនេះ ។ មានរឿងមួយដែលព្រះទ្រង់មានបន្ទូលអំពីការបង្កើតជាថ្មីរបស់ទ្រង់ នៅក្នុងជំពូកទី១នៃព្រះគម្ពីរលោកុប្បត្តិ ។

ព្រះគម្ពីរលោកុប្បត្តិ ១:២៦

រឿងនោះគឺបានរួមទាំងសាតាំង និងពពួកវិញ្ញាណអាក្រក់ទាំងអស់របស់វា ។ ព្រះទ្រង់បានចាប់យកមកវិញ នូវអំណាចគ្រប់គ្រងលើស្ថានសួគ៌ទាំងអស់ ព្រមទាំងការទទួលចក្រវាឡទាំងមូលនៅលើភពមួយ ។ នេះគឺជាអំណាចគ្រប់គ្រងដែលព្រះទ្រង់បានប្រទានឱ្យដល់មនុស្ស ដែលឥឡូវនេះគឺឱ្យបានដូច

ជាព្រះ ដើរដូចជានឹងព្រះ ព្រមទាំងនិយាយដូចជាព្រះនោះឯង ។ ផែនដីគឺនៅតែជាកម្មសិទ្ធិរបស់ព្រះ ប៉ុន្តែ ភាពជាស្តេចគឺត្រូវប្រទានឱ្យទៅមនុស្សដើម្បីគ្រប់គ្រង និងទទួលយកនូវអំណាចនេះ ។

នេះគឺជាហេតុផលដែលអារក្សបានស្អប់ ដល់មនុស្សជាតិជាខ្លាំងដល់ម្ល៉េះនោះ ។ នោះគឺជាអ្វីដែលមានសង្គ្រាមនៅលើផែនដីនេះ ។ តាមរយៈការឆបោក នោះសាតាំងបានប្រើល្បិចដល់លោកអ័ដាម និងនាងអេវ៉ាឱ្យធ្លាក់ចុះអទៅក្នុងការមិនស្តាប់បង្គាប់ព្រះ ។ នៅពេលដែលពួកគេបានធ្វើបាបទាស់ទទឹងនឹងព្រះ នោះជីវិតរបស់ព្រះក៏បានឃ្លាតចេញពីពួកគេ ហើយលោកអ័ដាម និងនាងអេវ៉ាក៏បានព្រមប្រគល់កូនសោរនៃសិទ្ធិអំណាច និងអំណាចគ្រប់គ្រងនៅលើផែនដី ដែលបានប្រទានមកឱ្យពួកគេនោះ ទៅសាតាំង ។

## ឃ.ផែនការក្នុងការកែមនុស្សជាតិជាថ្មីឡើងវិញ

មនុស្សជាតិក៏បានរស់នៅក្នុងស្ថានការណ៍អស់សង្ឃឹម ជាមួយនឹងភស្តុតាងបន្តិចបន្តួចនៃការចាប់ផ្តើមសិរីល្អរបស់ពួកគេជាមួយនឹងព្រះ ។ នៅលើផែនដីដែលមានពេញទៅដោយជម្ងឺ និងជម្ងឺរោគា ភាពទ័លក្រ ការជាប់ទោសចំពោះអំណាចរបស់សាតាំង ។

ទោះជាយ៉ាងណាក៏ដោយ ព្រះទ្រង់មិនអាចយាងមកជួសជុលបញ្ហានៅលើផែនដីនេះទេ គឺដោយសារតែទ្រង់បានប្រទានអំណាចគ្រប់គ្រងលើផែនដីនេះ ឱ្យទៅមនុស្សហើយ ។ នៅក្នុងប្រាជ្ញាដ៏ចម្បងរបស់ព្រះ ហើយគឺជាលទ្ធផលនៃសេចក្តីស្រឡាញ់ដ៏ធំឧត្តមរបស់ព្រះអង្គ ទើបព្រះអង្គទ្រង់មានផែនការសម្រាប់មនុស្សជាតិ ក្នុងការបង្កើតជាថ្មីរបស់ទ្រង់នោះ គឺទ្រង់បានបញ្ជូនព្រះរាជបុត្រាទ្រង់ ព្រះនាមព្រះយេស៊ូវឱ្យយាងមកផែនដី "យកកំណើតជាមនុស្ស" ។ គឺទ្រង់បានយាងមកជា "លោកអ័ដាមចុងក្រោយ" នោះឯង ។

ព្រះគម្ពីរ ១កូរិនថូស ១៥:៤៥

ព្រះយេស៊ូវទ្រង់បានយាងមកជាកូនមនុស្ស គឺដោយសារតែមនុស្សមានភាពដើម ដែលព្រះទ្រង់បានប្រទានឱ្យមានអំណាចគ្រប់គ្រងលើផែនដីនេះ ។

ព្រះគម្ពីរភីលីព ២:៥-៨

ទ្រង់បានយាងមកដើម្បីបំផ្លាញការងាររបស់អារក្ស ។ គ្រប់ទីកន្លែងដែលទ្រង់យាងទៅ ទ្រង់បានចាប់យកនូវអំណាចគ្រប់គ្រងលើផែនដីនេះ និងគ្រប់របស់ទាំងអស់ដែលនៅលើផែនដីនេះ ទ្រង់បានបញ្ជាទៅសមុទ្រនិងព្យុះឱ្យស្ងប់ទៅវិញ ។ ទ្រង់បានបណ្តេញអារក្សទាំងកងឱ្យចេញទៅ ។ ទ្រង់បានសុគតដើម្បីធ្វើជាអ្នកប្រោសលោះជំនួសយើង ។ ទ្រង់បានផ្ទុកនូវអំពើបាបរបស់យើង ដោយទ្រង់បានយាងទៅដល់ទីជម្រៅនៃផែនដី ។ នៅពេលដែលទ្រង់បានរស់ពីសុគតឡើងវិញ ទ្រង់ក៏បានធ្វើឱ្យម្ចាស់នៃលោកិយ និងអំណាចរបស់វាបានខូច ហើយក៏បានដាក់ពួកវានៅទីវាលដោយក្តីអាម៉ាស ។ ទ្រង់បានចាប់យកកូនសោរនៃអំណាចគ្រប់គ្រង ពីសាតាំងត្រឡប់មកវិញ និងបានប្រោសលោះដល់មនុស្សជាតិ ឱ្យធ្វើជាអ្នកដែលបានត្រូវបង្កើតជាថ្មី គឺជាពួកជំនុំរបស់ព្រះអង្គសព្វថ្ងៃនេះឯង ។

## ង. អំណាចគ្រប់គ្រងបានកែជាថ្មីឡើងវិញ គឺបានប្រោសលោះដល់មនុស្សជាតិ

ព្រះយេស៊ូវទ្រង់មានបន្ទូល នៅក្នុងព្រះគម្ពីរម៉ាថាយ ១៦:១៨-១៩ សិទ្ធិអំណាច និងអំណាចគ្រប់គ្រងលើផែនដីនេះ និងរបស់គ្រប់យ៉ាងនៅលើផែនដីនេះ បានត្រូវទទួលការ

កែជាថ្មីឡើងវិញហើយ ដើម្បីប្រោសលោះដល់មនុស្សជាតិ គឺរូបកាយរបស់ព្រះអង្គដែលជាពួកជំនុំនោះឯង ។ គោលបំណងរបស់ទ្រង់ គឺសម្រាប់មនុស្សជាតិបានកែជាថ្មីឡើងវិញ ។ ម្យ៉ាងទៀត ទ្រង់មានបន្ទូលថា: "ចូរឱ្យមានអំណាចគ្រប់គ្រងលើផែនដីនេះ និងរបស់គ្រប់យ៉ាងដែលនៅលើផែនដី" ។ កូនសោរនៃនគរនៅលើផែនដីនេះ បានត្រូវកែជាថ្មីឡើងវិញ ប្រគល់ឱ្យទៅមនុស្សជាតិ គឺជាការបង្កើតឡើងជាថ្មីរបស់ទ្រង់នោះឯង ។ ចំពោះពួកអ្នកជឿនៅសម័យសព្វថ្ងៃនេះ គឺយើងមានកូនសោរនៃអំណាចគ្រប់គ្រង ដើម្បីចងនិងស្រាយហើយ ។ ដើម្បីចង មានន័យថា កំណត់បាននូវតំបន់ខាងសិទ្ធិអំណាចរបស់អ្នកណាម្នាក់ ។ ព្រះទ្រង់បានប្រទានមកឱ្យពួកយើងម្នាក់ៗ នូវតំបន់ខាងសិទ្ធិអំណាច តំបន់ខាងអំណាចគ្រប់គ្រង តំបន់ភាពជាស្ដេច ។ ព្រះយេស៊ូវទ្រង់គឺជា "ស្ដេចលើអស់ទាំងស្ដេច" យើងរាល់គ្នាគឺជាស្ដេចនៅលើផែនដីនេះ សព្វថ្ងៃនេះ ។ ស្ដេចគឺត្រូវចាប់យកអំណាចគ្រប់គ្រង ត្រូវបង្ក្រាប ត្រូវគ្រប់គ្រងលើអាណាខេត្តដ៏ពិតប្រាកដ ដែលជាតំបន់ខាងឯសិទ្ធិអំណាចរបស់ពួកគេនោះឯង ។

### ១. ព្រះយេស៊ូវទ្រង់បានបំផ្លាស់បំប្រែសិទ្ធិអំណាចនោះ។

សព្វថ្ងៃនេះ យើងបានកើតជាថ្មីហើយ យើងមានតំបន់ខាងឯសិទ្ធិអំណាច នៅក្នុងជីវិតរបស់យើង ហើយ នៅក្នុងអាពាហ៍ពិពាហ៍ នៅក្នុងផ្ទះ និងនៅក្នុងក្រុមគ្រួសារ នៅជាមួយអ្នកជិតខាង នៅក្នុងទីក្រុង នៅក្នុងជាតិសាសន៍ នៅក្នុងទីកន្លែងរបស់យើង ដែលព្រះទ្រង់បានបញ្ជូនយើងឱ្យចេញទៅនោះ ។ មានតែរឿងមួយទេ ដែលសាតាំង និងពពួកវិញ្ញាណអាក្រក់របស់វា អាចនៅក្នុងតំបន់ខាងឯសិទ្ធិអំណាចបាន គឺជាអ្វីដែលយើងជាពួកជំនុំ នៃព្រះដ៏មានព្រះជន្មរស់ ដែលបានអនុញ្ញាតឱ្យវាធ្វើនោះ ។ យើងត្រូវការប្រើសិទ្ធិអំណាច ដែលព្រះទ្រង់បានប្រទានឱ្យមកយើងនោះ ។

ព្រះគម្ពីរលូកា ១០:១៩

ព្រះគម្ពីរ ២កូរិនថូស ១០:៤

### ២. យើងត្រូវដើរដោយការស្ដាប់បង្គាប់

ព្រះគម្ពីរយ៉ាកុប ៤:៧-៨

ពេលដែលយើងអធិស្ឋាន នោះយើងត្រូវការ "ចូលឱ្យជិតព្រះអង្គ ហើយទ្រង់ក៏នឹងចូលមកជិតអ្នកដែរ" ។ នៅពេលដែលទ្រង់យាងចូលមកជិតយើង គឺយើងនឹងស្ដាប់ឮសម្លេងរបស់ទ្រង់ ហើយយើងទទួលនូវការបើកសម្ដែង ពីបំណងព្រះហឫទ័យរបស់ព្រះ "ដូចជានៅស្ថានសួគ៌ដែរ" ។ អញ្ចឹងយើងបាននិយាយ ដោយមានពាក្យពេញដោយសេចក្ដីជំនឿ ចេញពីមាត់យើងទៅ គឺជាសេចក្ដីអធិស្ឋានឱ្យនគរបានជឿនទៅមុខនោះឯង ។ យើងដូចជាព្រះយេស៊ូវ គឺយើងមានតែនិយាយពីអ្វី ដែលយើងស្ដាប់ឮព្រះវរបិតានៃយើង ទ្រង់មានបន្ទូលប៉ុណ្ណោះ (យ៉ូហាន ១៤:១០) ។

## II. ការអធិស្ឋានដោយអំណាចរបស់ព្រះយេស៊ូវ

ពេលដែលព្រះយេស៊ូវទ្រង់បានស្ដាប់ឮពីព្រះវរបិតា នោះទ្រង់បានចាប់យកនូវអំណាចគ្រប់គ្រងលើផែនដីនេះ និងអ្វីៗដែលនៅលើវាផងដែរ ។ ពេលដែលព្រះយេស៊ូវទ្រង់បានទទួលពិធីជ្រមុជទឹកនៅក្នុងទន្លេយ័រដាន នោះអំណាចចេស្ដា

នៃព្រះវិញ្ញាណបរិសុទ្ធ បានយាងមកសណ្ឋិតលើទ្រង់ ។ ទ្រង់ក៏បានដើរដោយនូវសិទ្ធិអំណាចជាមនុស្សគ្រប់គ្រងលើសាតាំង (ជាអ្នកដែលស្វែងរកដើម្បីសម្លាប់ និងបំផ្លាញប៉ុណ្ណោះ) ។

### ក.ព្រះយេស៊ូវទ្រង់បានចាប់យកអំណាចគ្រប់គ្រង

**១. ឈ្នះលើកម្លាំងធម្មជាតិ**

ព្រះគម្ពីរម៉ាកុស ៤:៣៧-៣៩

**២. ឈ្នះលើដើរល្វា**

ព្រះគម្ពីរម៉ាថាយ ២១:១៩

**៣. ឈ្នះលើជម្ងឺ និងជម្ងឺរោគា**

ព្រះគម្ពីរម៉ាកុស ១:៤០-៤២

**៤. ការអស្ចារ្យទៅលើស្នាព្រះហស្តដោយមានបន្ទូល**

ព្រះគម្ពីរម៉ាកុស ៣:៣-៥ខ

**៥. ឈ្នះលើសេចក្តីស្លាប់**

ព្រះគម្ពីរយ៉ូហាន ១១:៤៣-៤៤

**៦. ឈ្នះលើពួកវិញ្ញាណអាក្រក់**

ព្រះគម្ពីរម៉ាថាយ ៨:៣១-៣២

### ខ.ព្រះយេស៊ូវ និងលោកមេទ័ព

លោកមេទ័ពបានយល់ពីសិទ្ធិអំណាច និងបានទទួលស្គាល់សិទ្ធិអំណាចដែលមាននៅក្នុងព្រះយេស៊ូវ ។

ព្រះគម្ពីរម៉ាថាយ ៨:៨-១០,១៣

លោកមេទ័ពបាននិយាយដោយនូវសិទ្ធិអំណាច ទៅកាន់កូនទាហានដែលនៅក្រោមបញ្ជាការរបស់គាត់ ដោយពាក្យបញ្ជាខ្លីៗយ៉ាងដូច្នេះៈ "ចូទៅ!" "ចូរមក!" "ចូរធ្វើការនេះ!" ។

### គ. ការបញ្ជាដោយនូវសិទ្ធិអំណាចរបស់ព្រះយេស៊ូវ

ព្រះយេស៊ូវទ្រង់បានអធិស្ឋាន និងបំពេញព្រះរាជកិច្ចដោយនូវសិទ្ធិអំណាច ដោយគ្រាន់តែប្រើពាក្យបញ្ជាខ្លីៗថាៈ "ចូរទៅ" "ចូរឱ្យបានជាស្អាតចុះ" "ចូរលាតដៃអ្នកទៅ" "កុំឱ្យមានផ្លែទៀតឱ្យសោះ" "ចូរឱ្យមានសេចក្តីសុខសាន្តចុះ" "ឡាសារអើយ ចូរចេញមក!" ហើយអធិស្ឋានឱ្យនគរបានជឿនទៅមុខ នោះយើងនៅតែរកឃើញដោយខ្លួនឯង ម្យ៉ាងទៀតយើងបានស្តាប់ឮមកពីព្រះ ។ ក៏បាននិយាយអធិស្ឋាន និងបំពេញការងារ ដោយការបង្គាប់បញ្ជាដោយពាក្យខ្លីៗនោះដែរ ។ ព្រះយេស៊ូវទ្រង់បានធ្វើគ្រប់ការទាំងអស់ គឺសុទ្ធតែជាការអស្ចារ្យរបស់ផងទ្រង់ ដែលទ្រង់បានប្រើអំណាចគ្រប់គ្រង ទ្រង់មានងារជាកូនមនុស្ស ហើយក៏បានទទួលអំណាចចេស្តាមកពីព្រះវិញ្ញាណបរិសុទ្ធ ។

## III. សិទ្ធិអំណាចសម្រាប់គ្រប់អ្នកជឿទាំងអស់

ព្រះយេស៊ូវ និងពួកសិស្សទ្រង់បានអធិស្ឋាន សូមឱ្យនគរបានជឿនទៅមុខ ដោយការប្រើប្រាសអំណាចគ្រប់គ្រងរបស់ពួកគេដែលបានប្រទានពរមកពីព្រះ ។ យើងក៏អាចធ្វើការអស្ចារ្យដូចគ្នា ដូចជាព្រះយេស៊ូវទ្រង់បានអនុវត្តក្នុងការកែអំណាចគ្រប់របស់យើងជាថ្មី ដោយនូវអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធនោះ ។

ព្រះគម្ពីរយ៉ូហាន ១៤:១២

ព្រះយេស៊ូវទ្រង់បានបញ្ជាទៅពួកសិស្សរបស់ទ្រង់ ឱ្យធ្វើការងាររបស់ទ្រង់ ។

ព្រះគម្ពីរម៉ាថាយ ១០:៨

## ក. សិទ្ធិអំណាចរបស់ពួកអ្នកជឿជំនាន់ដើម

### ១. លោកសាវ័កពេត្រុស

នៅក្នុងព្រះគម្ពីរកិច្ចការ យើងបានរកឃើញការងាររបស់ពួកអ្នកជឿជំនាន់មុន គឺជារបៀបដូចគ្នានេះដែរ ។ ពួកគេបាននិយាយដោយនូវសិទ្ធិអំណាចដោយការប្រើពាក្យបញ្ជាខ្លីៗ ។ គឺនិយាយដូចជាព្រះយេស៊ូវទ្រង់មានបន្ទូល និងបានធ្វើការងាររបស់ព្រះយេស៊ូវ ។

ព្រះគម្ពីរកិច្ចការ ៣:៦

លោកសាវ័កពេត្រុសបានអធិស្ឋាន ដោយនិយាយទៅរូបបុគ្គលរបស់នាងតេប៊ីថា ដែលស្លាប់ឱ្យរស់ឡើងវិញ គឺសម្រាប់អស់អ្នកណាដែលជឿនោះឯង ។ បន្ទាប់មក គាត់ក៏ស្រែកសំដៅទៅរកព្រះ ។

ព្រះគម្ពីរកិច្ចការ ៩:៤០

### ២. លោកសាវ័កប៉ុល

លោកសាវ័កប៉ុល បាននិយាយឱ្យគ្រូបន្ទាអាគមឈ្មោះអេលីម៉ាស ឱ្យទៅជាអ្នកខ្វាក់ផ្នែកថា: លោកសាវ័កប៉ុល មិនបាននិយាយដោយសេចក្ដីកំហឹងទេ គឺគាត់បាននិយាយពីអ្វី ដែលព្រះទ្រង់មានបន្ទូលប៉ុណ្ណោះ ។

ព្រះគម្ពីរកិច្ចការ ១៣:១០-១២

លោកសាវ័កប៉ុល បាននិយាយដោយនូវសិទ្ធិអំណាច ក្នុងការបំពេញការងារទៅកាន់មនុស្សពិការនៅឯក្រុងលីស្ត្រាថា: គាត់បានឃើញដោយនូវវិញ្ញាណ ដោយភ្នែកខាងឯព្រះវិញ្ញាណ ។

ព្រះគម្ពីរកិច្ចការ ១៤:៩-១០

អស់អ្នកណាដែលមានសេចក្ដីអធិស្ឋាន ឱ្យនគរបានជឿនទៅមុខ គឺបាននិយាយដោយសេចក្ដីក្លាហាន និងដោយនូវសិទ្ធិអំណាច ។

### ៣. ពួកអ្នកជឿជំនាន់មុនបានអធិស្ឋានដោយក្លាហានៈ

ព្រះគម្ពីរកិច្ចការ ៤:២៩-៣១

អារក្សចង់ឱ្យបាន នូវការប្រកបស្និទ្ធស្នាលជាមួយយើង ។ យើងត្រូវការមានភាពក្លាហានក្នុងការអធិស្ឋាន ឱ្យបានដូចជាព្រះយេស៊ូវ និងដូចជាពួកអ្នកជឿនៅជំនាន់នោះបានអធិស្ឋានដែរ ។ ព្រះទ្រង់បានឆ្លើយតប នូវសេចក្ដីអធិស្ឋានរបស់ពួកគេយ៉ាងឆាប់ ។ ព្រះគម្ពីរសុភាសិត ២៨:១ ។

## ខ. សិទ្ធិអំណាចរបស់យើងនៅសម័យសព្វថ្ងៃនេះ

សិទ្ធិអំណាចរបស់ព្រះយេស៊ូវ គឺត្រូវបានកែយើងជាថ្មីនៅសម័យសព្វថ្ងៃនេះហើយៈ ព្រះគម្ពីរលូកា ១០:១៩ ។

សេចក្ដីអធិស្ឋានឱ្យនគរបានជឿនទៅមុខ គឺតែងតែបាននិយាយដោយនូវពាក្យបញ្ជាខ្លីៗប៉ុណ្ណោះ ។ គឺមិនត្រូវការការអធិស្ឋានដដែលៗវែងពេកឡើយ ។

ព្រះគម្ពីរម៉ាថាយ ៦:៧-៨

ជាកូនសោរនោះគឺត្រូវតែឮមកពីព្រះ ហើយក្រោយមកទើបនិយាយទៅកាន់ការនោះ ដោយពាក្យបញ្ជាខ្លីៗប៉ុណ្ណោះ។ ចូរប្រើសិទ្ធិអំណាចដែលព្រះទ្រង់បានប្រទានឱ្យលោកអ្នក ។

ព្រះគម្ពីរសាស្តា ៥:២

## គ. ហោរាអេលីយ៉ា និងសិទ្ធិអំណាច

នៅពេលដែលហោរាអេលីយ៉ា បានប្រោសកូនឱ្យរស់ពីស្លាប់ឡើងវិញៈ ព្រះគម្ពីរពង្សាវតារក្សត្រ ១៧:២១-២២ ។

ហោរាអេលីយ៉ា មុនពេលដែលពួកសង្ឃរបស់ព្រះបាល នៅលើភ្នំកើមែល គឺដែលបានស្រែកយ៉ាងខ្លាំង ដោយសម្រែក និងអារសាច់ខ្លួនឯង អស់រយៈពេលមួយថ្ងៃពេញ ដោយគ្មានឃើញចម្លើយអ្វីណាមួយកើតឡើងនោះទេ ។ ក្នុងមួយរំពេចនោះ ហោរាអេលីយ៉ាក៏បានរៀបចំអាសនា និងថ្វាយដង្វាយរៀបចំរួចជាស្រេច និងឱ្យគេចាក់ទឹក ហើយក៏បានអធិស្ឋានដោយនូវសិទ្ធិអំណាចយ៉ាងខ្លី១:

ព្រះគម្ពីរពង្សាវតារក្សត្រ ១៨:៣៦-៣៩

នៅពេលដែលពួកបណ្តាជនរបស់ព្រះបានអធិស្ឋាន ដូចជាពួកអ្នកជឿទាំងនេះ នោះយើងក៏និយាយនូវសេចក្តីអធិស្ឋានឱ្យនគរបានជឿនទៅមុខនោះឯង ។ យើងនឹងឃើញលទ្ធផលដូចជាពួកគេបានឃើញលទ្ធផលនោះដែរ ។ បំណងព្រះហឫទ័យរបស់ព្រះ នឹងបានសម្រេចនៅផែនដីដូចជានៅស្ថានសួគ៌ដែរ ។

## ក្រុមពិភាក្សា

១. បន្ទាប់ពីមានការធ្លាក់ចុះ គឺនៅពេលដែលផែនដីមានពេញដោយជម្ងឺ និងជម្ងឺរោគា ភាពទ័លក្រ និងនៅក្នុងការជាប់ទោសរបស់សាតាំង តើហេតុអ្វីបានជាព្រះទ្រង់មិនយាង និងជួសជុលនូវបញ្ហានោះទៅ?

២. ចំពោះអំណាចគ្រប់គ្រងលើផែនដី:

ក. ហេតុអ្វីបានជាព្រះទ្រង់ប្រទានអំណាចគ្រប់គ្រង លើផែនដីមកឱ្យមនុស្ស?

ខ. បន្ទាប់ពីការធ្លាក់ចុះ តើអ្នកណាមានអំណាចគ្រប់គ្រងលើផែនដី?

គ. បន្ទាប់ពីការរស់ពីសុគតឡើងវិញ តើអ្នកណាមានអំណាចគ្រប់គ្រងលើផែនដី?

៣. ម្យ៉ាងទៀត យើងបានស្តាប់ឮមកពីព្រះ ចុះតើហេតុអ្វីបានជាយើងត្រូវតែរកឱ្យឃើញដោយខ្លួនឯង នូវការនិយាយ ការអធិស្ឋាន និងការបំពេញការងារ ដោយការបញ្ជាត្រឹមតែពាក្យខ្លី១?

## ការសិក្សាដោយខ្លួនឯង

នៅក្នុងមេរៀននេះ យើងបានសិក្សារៀនសូត្រថា ព្រះទ្រង់បានប្រទានមកយើងម្នាក់១នូវតំបន់ខាងផ្នែកសិទ្ធិអំណាចមកនោះ ។

១. ចូរសរសេរពីមធ្យោបាយខ្លះ១ ដែលលោកអ្នកអាចប្រើនូវសិទ្ធិអំណាច/អំណាចគ្រប់គ្រងរបស់លោកអ្នក ដែលព្រះទ្រង់បានប្រទានមក នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ។

២. តើនៅក្នុងតំបន់អ្វីនៃជីវិតរបស់លោកអ្នក ដែលបានទទួលនូវការត្រាស់ហៅមក ឱ្យមានសិទ្ធិអំណាច និងអំណាចគ្រប់គ្រងនោះ?

៣. តើអ្វីទៅ ដែលសាតាំងត្រូវបានអនុញ្ញាតឱ្យធ្វើនៅក្នុងតំបន់សិទ្ធិអំណាចរបស់លោកអ្នកនោះ?

# ការអធិស្ឋាន
# គឺជាការនាំយកស្ថានសួគ៌មកផែនដី
## *មេរៀនទី ៤: ការអធិស្ឋាន គឺជាសម្លេងនៃសេចក្ដីជំនឿ*

### I. ការអធិស្ឋានគឺជាការចង្អុលបង្ហាញពីសេចក្ដីជំនឿ ដែលគាប់ចល់ព្រះហឫទ័យព្រះ ។

### ក. ការអធិស្ឋានប្រកបដោយជំនឿ

ព្រះគម្ពីរយ៉ាកុប ៥:១៥ក

ព្រះគម្ពីរម៉ាកុស ១១:២៤

នៅពេលដែលយើងអធិស្ឋានដោយសេចក្ដីជំនឿ នោះយើងជឿថា យើងបានទទួលអ្វីដែលយើងបានទូលសូមនោះ។ សំណួរគឺៈ តើយើងមានសេចក្ដីជំនឿពិតប្រាកដ គឺជឿថាយើងនឹងបានទទួលអ្វីដែលយើងបានសូមដោយសេចក្ដីអធិស្ឋាននោះឬ?

ព្រះគម្ពីរម៉ាថាយ ២១:២២

ដូច្នេះ វាគឺជាការសំខាន់ដែលការអធិស្ឋាននោះគឺជាការបញ្ជាក់នូវសេចក្ដីជំនឿនោះឯង ។

### ខ. សេចក្ដីអធិស្ឋានដែលគាប់ដល់ព្រះហឫទ័យព្រះ

ព្រះគម្ពីរហេព្រើរ ១១:៦

សំណួរគឺ តើការអធិស្ឋានរបស់លោកអ្នកបានគាប់ដល់ព្រះហឫទ័យនៃព្រះឬទេ?

នៅក្នុងព្រះគម្ពីរវិវរណៈ យើងរកឃើញថា ការអធិស្ឋាននៃពួកបរិសុទ្ធ នោះគឺត្រូវតែដូចជាគ្រឿងក្រអូបនៅចំពោះបល្ល័ង្កនៃព្រះ ។

ព្រះគម្ពីរវិវរណៈ ៨:៣-៤

នៅពេលដែលខ្ញុំគិត អំពីសេចក្ដីអធិស្ឋានដែលគ្មានជំនឿ នោះខ្ញុំបានអធិស្ឋាន អស់រយៈពេលជាច្រើនឆ្នាំមកហើយ ជំនួសឱ្យនូវការនេះ គឺជាការហិតក្លិនយញ្ញបូជាដែលមានគ្រឿងក្រអូបចំពោះ ដែលទ្រង់ត្រូវតែទប់ច្រមុះរបស់ទ្រង់ដោយមានបន្ទូលថា "នោះគឺជាក្លិនស្អុយដ៏ពេញបន្ទុកហើយ!" ប្រសិនបើគ្មានសេចក្ដីជំនឿ នោះវាមិនអាចនឹងគាប់ដល់ព្រះហឫទ័យនៃព្រះបានឡើយ បន្ទាប់មក ការអធិស្ឋានដោយសេចក្ដីជំនឿ នោះគឺជាការជឿថា យើងបានទទួលអ្វីដែលយើងបានទូលសូមហើយ ពួកគេត្រូវតែនាំមកឯព្រះដែលជាការគាប់ព្រះទ័យដ៏ធំធេងនោះហើយ ។

### គ. សេចក្ដីអធិស្ឋានគឺដើរដោយនូវសេចក្ដីជំនឿ

សេចក្ដីជំនឿគឺមិនមែនជាការសួរថា ជឿលើព្រះនោះទេ ។ វាគឺជាសេចក្ដីទុកចិត្តដ៏ពេញលេញ និងជាការបញ្ជាក់ទៅលើព្រះ និងលើព្រះបន្ទូលរបស់ព្រះអង្គនោះឯង ។ សេចក្ដីជំនឿគឺជាការជឿនិងធ្វើសកម្មភាពទៅតាមព្រះបន្ទូលព្រះ ដោយគ្មានសំណួរ ឬដោយគ្មានការព្យាយាមរកហេតុផលនោះឡើយ ។

ព្រះគម្ពីរ ២កូរិនថូស ៥:៧

### II. ការរស់នៅក្នុងពាក្យពីរម៉ាត់

ពេលដែលយើង "បានកើតជាថ្មី" គឺយើងបានកើតមកពីព្រះវិញ្ញាណ ។ ប៉ុន្តែ យើងនៅតែរស់នៅខាងរូបកាយផ្នែកសាច់ឈាមរបស់យើងដដែលទេ ។

ព្រះគម្ពីរយ៉ូហាន ៣:៦

យើងបានកើតជាថ្មីនៅក្នុងព្រះគ្រីស្ទយេស៊ូវហើយ ។ រីឯរូបកាយខាងធម្មជាតិរបស់យើង គឺបានយល់ដឹងពីលោកិយ

ដែលនៅជុំវិញយើង ជាមួយវិញ្ញាណខាងធម្មជាតិទាំង៥របស់យើង ។ ចំពោះរូបកាយខាងធម្មជាតិ គឺជាតំបន់ដែលបានដឹងតាមអ្វីដែលយើងអាចមើលឃើញ ស្តាប់ឮ ហិតក្លិន ប៉ះពាល់ និងដឹងរសជាតិតែប៉ុណ្ណោះ ។

ទោះជាយ៉ាងណាក៏ដោយ ការបានកើតមកពីវិញ្ញាណគឺជាតំបន់ ដែលយើងបានរស់នៅខាងឯវិញ្ញាណនោះឯង ។ វិញ្ញាណរបស់លោកិយនោះ ក៏ជាការអស់កល្បដែរ ។ វាមានតំបន់ខាងធម្មជាតិនៅលោកិយនេះជាច្រើនទៀត ។ នៅតំបន់ខាងឯវិញ្ញាណ យើងក៏មានវិញ្ញាណទាំង៥ផងដែរ ។ តំបន់ដ៏ពិតប្រាកដខាងញាវិញ្ញាណ ក៏មានការបើកសម្តែងនៅក្នុងព្រះបន្ទូលព្រះដែរ ។ ដោយនូវព្រះវិញ្ញាណបរិសុទ្ធនោះ យើងអាច "មើលឃើញ" នូវលោកិយដ៏អស់កល្បខាងឯវិញ្ញាណ តាមរយៈការនិម្មិត ការយល់សប្តិ និងការបើកសម្តែងនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ យើងអាច "ស្តាប់ឮ" សម្លេងរបស់ព្រះ ។ យើងអាចហិតក្លិនបានដូចជាក្លិនក្រអូបនៃព្រះវិញ្ញាណបរិសុទ្ធ ។ យើងក៏អាចហិតក្លិនបាននូវវត្តមានរបស់ពួកវិញ្ញាណអាក្រក់ផងដែរ ។ យើងអាច "ប៉ះពាល់" បាននូវតំបន់នៃលោកិយខាងឯវិញ្ញាណ ។ យើងអាច "ហិតក្លិន" បាននូវកិច្ចការងារដ៏ល្អរបស់ព្រះ ។

ព្រះគម្ពីរទំនុកដំកើង ៣៤:៨

យើងរស់នៅក្នុងលោកិយទាំងពីរនេះ ប៉ុន្តែ រឿងរ៉ាវខាងឯវិញ្ញាណ ក៏មានតំបន់ជាច្រើនដែលយើងអាចដឹងដោយមានវិញ្ញាណខាងឯធម្មជាតិរបស់យើងនោះដែរ ។

## ក. សេចក្តីពិតគឺបានដោះយើងឱ្យមានសេរី ។

វិញ្ញាណខាងឯធម្មជាតិរបស់យើង ក៏ដឹងនូវហេតុការណ៍ផងដែរ ។ ប៉ុន្តែ វិញ្ញាណខាងឯវិញ្ញាណរបស់យើងក៏នូវសេចក្តីពិតផងដែរ ។ មានតែសេចក្តីពិតទេដែលអាចធ្វើឱ្យយើងមានសេរីភាព ។

ព្រះគម្ពីរយ៉ូហាន ៨:៣២

រីឯហេតុការណ៍មិនអាចដោះយើង ឱ្យមានសេរីភាពបាននោះទេ ។ សេចក្តីពិតនឹងដោះយើងឱ្យមានសេរីភាព ។ រឿងរ៉ាវខាងឯវិញ្ញាណ គឺជាការឆ្លងលើលាដល់គំនិតខាងឯធម្មជាតិ ដែលមិនអាចមានការរំឭកបានខាងឯវិញ្ញាណនោះបានឡើយ ។

ព្រះគម្ពីរ ១កូរិនថូស ២:១៤

ព្រះគម្ពីររ៉ូម ១២:១-២

## ខ. យើងមានជម្រើស

តើយើងមានបំណងនឹងជឿលើហេតុការណ៍ ដែលយើងដឹងពីការនោះ ដោយមានវិញ្ញាណខាងឯធម្មជាតិរបស់យើងនោះឬ? ឬក៏យើងមានបំណងនឹងជឿលើសេចក្តីពិត ដែលជាការបើកសម្តែងដល់យើង តាមរយៈព្រះបន្ទូលរបស់ព្រះ និងតាមរយៈវិញ្ញាណខាងឯវិញ្ញាណរបស់យើង?

## III. ការយល់ដឹងនូវសេចក្តីជំនឿ

## ក. សេចក្តីជំនឿគឺប្រឆាំងនឹងសេចក្តីសង្ឃឹម

សេចក្តីជំនឿគឺមិនមែនដូចគ្នានឹងសេចក្តីសង្ឃឹមទេ ។ រីឯសេចក្តីសង្ឃឹមវិញ គឺសម្លឹងមើលទៅខាងមុខ ។ សេចក្តីជំនឿគឺតែងតែមានក្នុងពេលឥឡូវនេះវិញ ។

ព្រះគម្ពីរហេព្រើរ ១១:១

ពេលដែលសេចក្តីជំនឿចូលមក គឺវាត្រូវរើចេញនូវរឿងរ៉ាវទាំងឡាយ ដែលយើងបានមានសង្ឃឹមសម្រាប់ពេលខាង

មុខនោះ នៅក្នុងតំបន់នៃ "ពេលឥឡូវនេះ" ។ គ្មានប្រភេទនៃសេចក្តីជំនឿដទៃទៀតទេ គឺមាន "សេចក្តីជំនឿនៅពេលឥឡូវនេះ" វិញ ។ សេចក្តីសង្ឃឹមគឺជាការទន្ទឹងរង់ចាំនូវ "សាច់រឿង" ដែលយើងសម្រេចចិត្តនោះ ។ សេចក្តីជំនឿគឺជា "សាច់រឿង" តែប៉ុណ្ណោះ ។ សេចក្តីសង្ឃឹមគឺបានថែងមកថា "ខ្ញុំនឹងបានទទួលវានៅថ្ងៃណាមួយ" ។ រីឯសេចក្តីជំនឿវិញ គឺបានថែងមកថា "ខ្ញុំមានសេចក្តីជំនឿនៅពេលនេះឯង!" ព្រះយេស៊ូវទ្រង់មិនបានមានព្រះបន្ទូលទៅកាន់ស្ត្រីដែលបានទទួលនូវការប្រោសឱ្យជា ដោយការប៉ះពាល់ព្រះអង្គនោះទេថា "កូនស្រីអើយ សេចក្តីសង្ឃឹមរបស់នាងបានប្រោសនាងឱ្យជានោះទេ" ប៉ុន្តែ ទ្រង់មានព្រះបន្ទូលយ៉ាងនេះវិញថា "សេចក្តីជំនឿរបស់នាងបានប្រោសឱ្យនាងជា" វិញ ។

វាបានថែងមកយ៉ាងដូច្នេះ "សេចក្តីសង្ឃឹមបានជ្រើសរើសយកយុទ្ធសាស្ត្រ រីឯសេចក្តីជំនឿគឺនាំមកនូវលទ្ធផល" ។

## ខ. តើសេចក្តីជំនឿគឺជាអ្វី?

ទោះជាយ៉ាងណាក៏ដោយ ក៏សេចក្តីជំនឿមិនតម្រូវទៅលើការមើលឃើញនោះដែរ គឺជាការបើកសម្តែងភ្លាមៗចំពោះវិញ្ញាណខាងឯធម្មជាតិរបស់យើងនោះវិញ ។ គឺជំនួសឱ្យនូវការដែលយើងមើលឃើញ តាមរយៈភ្នែកនៃសេចក្តីជំនឿរបស់យើងនោះឯង ។ សេចក្តីជំនឿគឺជាការបញ្ជាក់ពីរបស់ដែលមើលមិនឃើញ (នឹងភ្នែកខាងឯធម្មជាតិ)។ ការមើលឃើញនឹងភ្នែកខាងឯធម្មជាតិ គឺជាការបញ្ជាក់ពីការដឹងតែប៉ុណ្ណោះ ។

ព្រះគម្ពីរហេព្រើរ ១១:៣

ពិភពលោកទាំងមូលគឺកើតឡើងពីរបស់ដែលមើលដោយភ្នែកខាងឯធម្មជាតិ ។ សេចក្តីជំនឿគឺមាននៅក្នុងតំបន់ខាងឯវិញ្ញាណ ។ សេចក្តីជំនឿគឺមានសារធាតុខាងឯវិញ្ញាណ ។ ឥឡូវនេះ សេចក្តីជំនឿគឺជាសារធាតុមួយ ដែលបញ្ជាក់ពីរបស់ដែលមើលមិនឃើញ ដោយភ្នែកខាងឯធម្មជាតិ ។ សារធាតុខាងឯវិញ្ញាណ គឺពិតប្រាកដជាងវិញ្ញាណរបស់មនុស្សជាសារធាតុខាងឯធម្មជាតិ គឺត្រូវជាមនុស្សខាងឯធម្មជាតិនោះឯង ។ យើងចំណាយពេលនៅក្នុងព្រះវត្តមាននៃព្រះច្រើនប៉ុណ្ណា នោះវិញ្ញាណខាងឯវិញ្ញាណរបស់យើង ក៏នឹងមានការអភិវឌ្ឍន៍ច្រើនប៉ុណ្ណោះដែរ ។ យើងជញ្ជឹងគិតពិចារណានៅក្នុងព្រះបន្ទូលច្រើនប៉ុណ្ណា នោះរឿងរ៉ាវខាងឯវិញ្ញាណក៏នឹងត្រូវបានត្រឡប់មកជាពិតប្រាកដ នៅក្នុងចិត្តរបស់យើងច្រើនប៉ុណ្ណោះដែរ ។ ភ្នែកនិងត្រចៀកខាងឯវិញ្ញាណរបស់យើងគឺបានត្រឡប់មកជាការប្រគុំដ៏ច្រើន ចូលទៅក្នុងតំបន់ខាងឯវិញ្ញាណ ។ វាបានត្រឡប់ទៅជាងាយស្រួលជាជាង ដើម្បីឱ្យបានមើលឃើញរឿងរ៉ាវខាងឯវិញ្ញាណ និងស្តាប់ឮសម្លេងរបស់ព្រះ ។

## គ. របៀបណាដែលសេចក្តីជំនឿចូលមក

ព្រះគម្ពីររ៉ូម ១០:១៧

សេចក្តីជំនឿគឺមិនមែនចូលមក ដោយការផ្ចង់ចិត្តទៅលើបញ្ហា កាលៈទេសៈ ការសង្ស័យ និងការភ័យខ្លាចនោះទេ ។ ដើម្បីឱ្យបានយល់ដឹងពីការនេះកាន់តែច្រើនទៀត នោះយើងត្រូវតែយល់ដឹងពីពាក្យជាភាសាក្រិកដើម ដែលបានប្រើនៅពេលដែលនិយាយពី "ព្រះបន្ទូល" របស់ព្រះ ។ ពាក្យដែលបានប្រើនៅទីនេះ គឺមិនមែនជាពាក្យ "ឡូកូស" ដែលជាព្រះបន្ទូលរបស់ព្រះ ដែលបានថែងមកជាទូទៅនោះទេ ។ ជំនួសឱ្យនូវពាក្យដែលបានប្រើនៅទីនេះ គឺជាពាក្យ "រេម៉ា" ជារបស់ព្រះនោះទេ ។

**១. ឡូកូស(Logos)**

ពាក្យ "ឡូកូស" គឺជាបំណងព្រះហឫទ័យរបស់ព្រះ ដែលបានចែងមកនៅក្នុងព្រះគម្ពីរ ។

**២. រេម៉ា(Rhema)**

ពាក្យ "រេម៉ា" គឺជាពាក្យពិសេសបន្ថែមទៀត ។ ពាក្យ "រេម៉ា" គឺជាពាក្យឯកវចនៈ ។ វាជាពាក្យឯកវចនៈ ហើយជាពាក្យនិយាយជាលក្ខណៈបុគ្គលដែលចូលមកដោយការបើកសម្តែង ចូលទៅក្នុងវិញ្ញាណរបស់យើង ។ វាគឺជា "រេម៉ា" ដែលយើងស្តាប់ឮ ជាមួយនឹងត្រចៀកខាងឯវិញ្ញាណរបស់យើង ហើយត្រូវតែចាប់យកជាមួយនឹងយើង ពេលដែលយើងអធិស្ឋាននោះឯង ។

ព្រះគម្ពីរអេភេសូរ ៦:១៦-២០

## ឃ. ការផ្លាស់ប្រែជីវិតនៃការអធិស្ឋានរបស់យើង

**១. ព្រះបន្ទូលបានត្រឡប់មកជាតួបុគ្គល ។**

យើងត្រូវតែចាប់យក "រេម៉ា" ឬពាក្យសម្តីដែលនិយាយជាលក្ខណៈបុគ្គល ដែលបានត្រូវបើកសម្តែងដល់យើង ពេលដែលយើងអធិស្ឋាន ។ នៅពេលដែលយើងបានទទួលនូវការបើកសម្តែងពី "រេម៉ា" របស់ព្រះ ក្នុងមួយរំពេចនោះ "ពន្លឺ" ក៏បានចៀសចេញទៅ រីឯសេចក្តីពិតនៃពាក្យ ឡូកូស គឺជាការលោតផ្លោះទៅទំព័រព្រះគម្ពីររបស់យើង ហើយសេចក្តីជំនឿ នឹងចូលមកឯវិញ្ញាណរបស់យើង ។ យើងនឹងនិយាយថា "វ៉ាវ" នេះគឺជាចម្លើយរបស់ខ្ញុំ! នោះគឺជាអ្វីដែលខ្ញុំបានរកមើលនោះឯង! នៅពេលនោះ សេចក្តីជំនឿក្នុងមួយខណៈនោះ គឺបានលោតចូលទៅក្នុងវិញ្ញាណរបស់យើង ។ ស្នូរចេញពីមាត់របស់យើង គឺត្រូវប្រទានឱ្យមកយើងហើយ ។ យើងបើកមាត់របស់យើង ហើយចាប់ផ្តើមនិយាយដោយអង់អាចពីសេចក្តីអធិស្ឋានឱ្យនគរ បានជឿនទៅមុខនោះឯង។

នៅពេលដែលយើងបានទទួលជាក្យរេម៉ា ដោយការបើកសម្តែង នោះពាក្យ ឡូកូស ក៏បានរើចេញពីព្រះគម្ពីររបស់យើង ហើយគំនិតរបស់យើងក៏បានចូលទៅក្នុងចិត្តរបស់យើងដែរ ។ ក្នុងមួយរំពេចនោះ សេចក្តីជំនឿ ក៏បានលោតចូលទៅក្នុងវិញ្ញាណរបស់យើង ហើយយើងក៏ចាប់ផ្តើមនិយាយពាក្យនោះ ហើយ "ការរស់នៅ" ក៏ដោយសារសេចក្តីជំនឿនោះឯង ។

ព្រះគម្ពីរម៉ាថាយ ៤:៤

យើងក៏បានចាប់ផ្តើមនិយាយពាក្យ ដែលបានចូលទៅក្នុងចិត្តរបស់យើងនោះ ហើយក៏បាននិយាយចេញពីមាត់យើងទៅ ដោយសេចក្តីក្លាហាន ។ រេម៉ាដែលបានកត់ត្រាទុក គឺជាការនិយាយនោះឯង ។

ព្រះគម្ពីរម៉ាកុស ៦:៤៥

**២. ការផ្លាស់ប្រែដ៏ពិតប្រាកដ**

ជីវិតនៃសេចក្តីអធិស្ឋានរបស់យើង គឺបានផ្លាស់ប្រែដ៏ពិតប្រាកដហើយ ។ យើងបានត្រឡប់ទៅជាសម្លេង ចូលទៅក្នុងតំបន់ដ៏ពិតប្រាកដ នៃនគរស្ថានសួគ៌នោះហើយ ។ យើងកំពុងតែបានស្តាប់ឮមកពីព្រះ។ សេចក្តីជំនឿ គឺបានលោតចូលទៅក្នុងវិញ្ញាណ

របស់យើងហើយ ។ វាគឺជាសេចក្តីជំនឿដែលគាប់ដល់ព្រះហឫទ័យនៃព្រះ ។ យើងបានបើកមាត់របស់យើង ដោយសេចក្តីក្លាហាន ក្នុងការអធិស្ឋានហើយ។ យើងបានចាប់ផ្តើមបង្កើតផលផ្លែ ពីបបូរមាត់របស់យើងហើយ ។

ព្រះគម្ពីរអេសាយ៥៧:១៩ក

ព្រះគម្ពីរសុភាសិត ១៨:២១

ព្រះគម្ពីរហេព្រើរ ១១:៣

ព្រះទ្រង់ជាអ្នកបង្កើត ។ យើងរាល់គ្នា គឺត្រូវបានបង្កើតមកនៅក្នុងរូបភាពរបស់ព្រះអង្គ ។ ព្រះទ្រង់បានបង្កើតដោយមានព្រះបន្ទូល ដែលចេញមកតាមរយៈព្រះឱស្ឋរបស់ទ្រង់ ។ យើងក៏អាចបង្កើតតាមរយៈពាក្យសម្តី ដែលចេញពីមាត់របស់យើងមកដែរ នៅក្នុងសេចក្តីអធិស្ឋាន ។ យើងបង្កើតផលផ្លែពីបបូរមាត់របស់យើង ។

## ៣. សំណួរសម្រាប់ការផ្លាស់ប្រែ

តើយើងត្រូវបាន "បង្កើត" មកដោយជីវិតនៃការបំផ្លាស់បំប្រែជាដំបូងរបស់យើង យ៉ាងដូចម្តេចដែរ? តើយើងបាននិយាយដោយការសង្ស័យ ដោយការភ័យខ្លាច និងដោយមានបញ្ហារបស់យើងឬ? តើយើងបាននិយាយដោយមាន "សេចក្តីស្លាប់" ក្នុងពេលដែលយើងបាននិយាយពី "ជីវិត" ឬទេ? តើអ្វីទៅដែលយើងបានត្រូវបង្កើតមកដោយ "ផលផ្លែនៃបបូរមាត់របស់យើង" នៅពេលដែលយើងបានអធិស្ឋានឬ?

តើអណ្តាតរបស់យើងត្រូវបានបញ្ចេញទៅ ដោយ "អំណាចនៃសេចក្តីស្លាប់" ឬក៏ដោយ "អំណាចនៃជីវិត" ?

ព្រះគម្ពីរសុភាសិត ៦:២

ព្រះគម្ពីរសុភាសិត ១៨:៧

អស់រយៈពេលជាច្រើនឆ្នាំណាស់មកហើយ ដែលខ្ញុំបានអធិស្ឋាន គឺដោយមានបញ្ហា និងការភ័យខ្លាចនោះឯង ។ ខ្ញុំបានធ្វើការផ្តឹងផ្តល់ជាមួយនឹងព្រះ ។ ខ្ញុំមិនអាចបង់ថ្លៃសម្រាប់វិក័យប័ត្ររបស់ខ្ញុំនោះទេ ។ ខ្ញុំតែងតែមានជម្ងឺនៅក្នុងកំឡុងឆ្នាំនេះ ។ ពួកកូនរបស់ខ្ញុំក៏ចេះតែធ្វើការបះបោរជាច្រើន ។ ល្មមគ្រប់គ្រាន់ចំពោះអ្វីដែលកើតឡើងនោះហើយ ។ ខ្ញុំបានអធិស្ឋានពីបញ្ហារបស់ខ្ញុំ ។ ខ្ញុំបានគិតថា ខ្ញុំត្រូវតែទូលសូមព្រះឱ្យជួយហើយ ។

ពួកកូនចៅអ៊ីស្រាអែលដែលបះបោរនោះ គឺបានទទួលនូវការមួយដ៏ប្រាកដ ពីអ្វីដែលពួកគេបាននិយាយ ជាមួយនឹងបបូរមាត់មិនជឿរបស់ពួកគេនោះ ។

ព្រះគម្ពីរជនគណនា ១៤:២

ព្រះគម្ពីរជនគណនា ១៤:២៨-២៩

ខ្ញុំបានកំពុងតែរទូរទាំ និងបានកំពុងតែត្អូញត្អែរជារឿយៗ។ ខ្ញុំមានជម្ងឺ និងអស់កម្លាំងដោយសារជម្ងឺ ខ្ញុំអស់កម្លាំងណាស់ ។ ការទាំងនោះវាចេះតែចូលមករកខ្ញុំ ជាទីបំផុត ។

## ៤. ការអធិស្ឋាន គឺជាផ្លូវរបស់របស់ព្រះ

ព្រះគម្ពីរសុភាសិត ១៣:៣

ព្រះគម្ពីរសុភាសិត ១៦:២៣

នៅក្នុងសេចក្តីអធិស្ឋាន ដ៏ពេញដោយសេចក្តីជំនឿ នោះចិត្តរបស់យើង និងមាត់របស់យើងបានធ្វើការយល់ ជាមួយនឹងព្រះបន្ទូលរបស់ព្រះ ។ យើងត្រូវតែសិក្សា ដើម្បីឱ្យបានស្គាល់ពីព្រះបន្ទូលរបស់ព្រះ ។ បន្ទាប់មក ភាពពេញលេញនៃចិត្តរបស់យើង គឺអាចត្រូវបានទទួលនូវការបើកសម្តែង ។ ពាក្យរបស់យើង គឺជាលទ្ធផលនៃការជញ្ជឹងគិតរបស់យើងទៅលើព្រះបន្ទូលរបស់ព្រះ ។ បន្ទាប់មក យើងនឹងបានបង្កើតផលផ្លែល្អ ។

ព្រះគម្ពីរទំនុកដំកើង ១៩:១៤

ពាក្យដែលចេញពីមាត់របស់យើង គឺជាលទ្ធផលនៃការជញ្ជឹងគិតពិចារណាពីចិត្តរបស់យើង ។

ព្រះគម្ពីររ៉ូម ១០:៩

ពាក្យដែលចេញពីមាត់របស់យើង គឺនាំមកនូវសេចក្តីសង្គ្រោះរបស់យើង ។

ពាក្យ "សេចក្តីសង្គ្រោះ" នៅទីនេះគឺជាពាក្យភាសាក្រិកថា "សូហ្សូ" គឺវាមានន័យថា បានសង្គ្រោះ បានប្រោសឱ្យជា និងបានរំដោះឱ្យរួច ឬក៏ដោះឱ្យមានសេរីភាព ។ នៅពេលយើងស្តាប់ព្រះវរបិតា ហើយទទួលនូវពាក្យ រេម៉ា នោះសេចក្តីជំនឿក៏បានលោតចូលមកក្នុងចិត្តរបស់យើង ហើយយើងក៏ចាប់ផ្តើមសារភាព ឬប្រកាសពីការនោះចេញពីមាត់យើង ដោយសេចក្តីអធិស្ឋាននោះឯង ។

ឥឡូវនេះ ជីវិតនៃសេចក្តីអធិស្ឋានរបស់យើងបានចាប់យកនូវអត្ថន័យថ្មីទាំងស្រុងហើយ ។ ឥឡូវនេះ យើងកំពុងតែស្តាប់ ជាមួយនឹងតំបន់ខាងឯវិញ្ញាណរបស់យើងនោះឯង ។ បំណងព្រះហឫទ័យរបស់ព្រះ "គឺដូចជានៅស្ថានសួគ៌ដែរ" គឺជាការបើកសម្តែងមកដល់យើង ។ ឥឡូវនេះ យើង"កំពុងតែនិយាយ" ពីអ្វីដែលយើងបានឮពីព្រះវរបិតា ទ្រង់មានបន្ទូល ។ ឥឡូវនេះ គឺនៅពេលយើងអធិស្ឋាន នោះយើងមិននិយាយពីបញ្ហាច្រើនពេចទេ ។ យើងនិយាយពីពាក្យ "រេម៉ា" ដែលព្រះទ្រង់បានមានបន្ទូលមកកាន់វិញ្ញាណរបស់យើង ។ យើងមើលឃើញដោយភ្នែកខាងឯវិញ្ញាណរបស់យើង ស្តាប់ឮដោយត្រចៀកខាងឯវិញ្ញាណរបស់យើង និយាយដោយការព្រមព្រៀង ជាមួយនឹងពាក្យដែលយើងបានឯកភាពនោះ គឺដែលយើងបានមើលឃើញ និងស្តាប់ឮដោយវិញ្ញាណនោះឯង ។ សេចក្តីអធិស្ឋានគឺត្រូវការនូវការស្តាប់ពីសេចក្តីអធិស្ឋាន ដោយនូវការទទួលខុសត្រូវ ពីបំណងព្រះហឫទ័យរបស់ព្រះមកនោះឯង ។ យើងត្រូវការនិយាយពីអ្វី ដែលយើងស្តាប់ឮព្រះទ្រង់មានបន្ទូល ។

ព្រះគម្ពីរ ២កូរិនថូស ៤:១៣

ពេលដែលយើងនិយាយ ពីព្រះបន្ទូលរបស់ព្រះដែលមានជីវិតរស់នៅ និងមានពេញដោយអំណាចចេស្តា នោះវានឹងតែងតែផលិតនូវលទ្ធផលទាំងនោះ ។ ពេលដែលយើងនិយាយពីព្រះបន្ទូលរបស់ព្រះ នោះយើងកំពុងតែបញ្ជូនវា ឱ្យទទួលស្គាល់នូវបំណងព្រះហឫទ័យរបស់ព្រះ ។ វានឹងត្រូវតែបំពេញនូវគ្រប់តែកន្លែងចន្លោះ ហើយនាំមកនូវសេចក្តីចម្រុងចម្រើន ទៅគ្រប់អស់ទាំងស្ថានការណ៍ទាំង

នោះ ។ ដូច្នេះ យើងជឿ ហើយយើងនិយាយពីព្រះបន្ទូលព្រះ ។ យើងបានស្តាប់ឮមកពីព្រះ ហើយនិយាយពីអ្វីដែល យើងបានស្តាប់ឮមកពីពាក្យ រេម៉ា នោះឯង ។ ដូច្នេះ យើងជឿ ហើយយើងនិយាយ ។ ការអធិស្ឋាន គឺជាការបំផ្លាស់បំប្រែរឿងរ៉ាវ និងស្ថានការណ៍ទាំងនោះ ។ យើងអាចអធិស្ឋានដោយអង់អាច គឺជាសេចក្តីអធិស្ឋានឱ្យនគរបានជឿនទៅមុខនោះឯង ។ ផលផ្លែនៃបបូរមាត់របស់ខ្ញុំ គឺត្រូវបង្កើតការត្រាស់ហៅពីរបស់គ្រប់យ៉ាង ដែលពួកគេមិនធ្លាប់មានមកនោះ ។ សូមឱ្យបំណងព្រះហឫទ័យទ្រង់ បានសម្រេចនៅផែនដី ដូចជានៅស្ថានសួគ៌ដែរ ។ ពួកទេវតាបានស្តាប់នូវសម្លេងរបស់ព្រះអម្ចាស់ ហើយក៏បានទទួលស្គាល់នូវព្រះរាជបញ្ជារបស់ព្រះអង្គ ។ សេចក្តីអធិស្ឋានរបៀបនេះហើយ ដែលគាប់ដល់ព្រះហឫទ័យនៃព្រះ ។ គឺជាការជញ្ជឹងគិតពិចារណានូវព្រះបន្ទូលព្រះអង្គ ទាំងថ្ងៃទាំងយប់នោះឯង ។ សេចក្តីជំនឿបានមកដោយការឮព្រះបន្ទូលព្រះ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលថា ចៀមខ្ញុំវាស្តាប់ឮសម្លេងរបស់ខ្ញុំ ។ ព្រះទ្រង់បានប្រទានឱ្យយើងនូវអំណាចគ្រប់គ្រងនៅទីនេះ គឺនៅលើផែនដីនេះឯង ។ ការបើកសម្តែងនេះ គឺជាការបំបះបំបោរនូវជីវិតរបស់ខ្ញុំ ។

ព្រះគម្ពីរអេសាយ ៥៥:១១

សូមឱ្យរាជ្យទ្រង់បានមកដល់ សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេចនៅផែនដី ដូចជានៅស្ថានសួគ៌ដែរ ។

## ក្រុមពិភាក្សា

១. តើមានន័យយ៉ាងដូចម្តេច ដែលសេចក្តីអធិស្ឋានរបស់យើង ត្រូវតែធ្វើឱ្យបានដូចជាគ្រឿងក្រអូប នៅចំពោះបល្ល័ង្កនៃព្រះនោះ?

២. ចូរពិភាក្សាពីរបៀបដើរតាមសេចក្តីពិត: "សេចក្តីសង្ឃឹមគឺជាដំណាក់ការជ្រើសរើស រីឯសេចក្តីជំនឿវិញ គឺជាលទ្ធផល" ។

៣. មានមនុស្សពីរនាក់នៅក្នុងក្រុម ចែកចាយទីបន្ទាល់ជាដំបូងអំពីរបៀបប្រើពាក្យរេម៉ា ដែលបានផ្លាស់ប្រែស្ថានការណ៍របស់ពួកគេនោះ ។

## ការសិក្សាដោយខ្លួនឯង

១. ចូរគិតអំពីរឿងរ៉ាវពិសេសៗខ្លះ ដែលលោកអ្នកទើបនឹងបានអធិស្ឋានអំពីរឿងរ៉ាវថ្មីៗបំផុត ។

ក. តើលោកអ្នកបានត្រូវបង្កើតអ្វីខ្លះ តាមរយៈផលផ្លែពីបបូរមាត់របស់លោកអ្នក?

ខ. តើអណ្ដាតរបស់លោកអ្នកបានកំពុងតែបញ្ចេញ នូវ "អំណាចនៃជីវិត" ឬក៏ "អំណាចនៃសេចក្ដីស្លាប់"?

២. តើតំបន់ពីរបីអ្វីខ្លះ ដែលមាននៅក្នុងជីវិតរបស់លោកអ្នក ចូលទៅក្នុងកន្លែងដែលលោកអ្នកញត្រូវការនិយាយពីព្រះបន្ទូលរបស់ព្រះ? គោលបំណងចំពោះការអធិស្ឋានគឺមានតែបំណងព្រះហឫទ័យរបស់ព្រះ ទៅលើតំបន់ទាំងនោះ ចំពោះកាលបរិច្ឆេទពិសេសមួយ ដែលលោកអ្នកសម្រេចចិត្តនោះ ។ ចូរស្វែងរកឱ្យឃើញ នូវព្រះបន្ទូលដែលត្រឡប់មកឯសេចក្ដីអធិស្ឋានរបស់លោកអ្នកវិញ ។

៣. នៅក្នុងមេរៀននេះ យើងសិក្សាពីព្រះដែលទ្រង់បានប្រទានដល់យើងម្នាក់ៗ នូវតំបន់ខាងសិទ្ធិអំណាចនោះ ។ ចូរសរសេរពីមធ្យោបាយខ្លះៗ ដែលលោកអ្នកអាចប្រើប្រាស់នូវអំណាចគ្រប់គ្រង និងភាពជាស្ដេចរបស់លោកអ្នកដែលព្រះទ្រង់បានប្រទានមក នៅក្នុងជីវិតប្រចាំថ្ងៃនោះ ។

# ការអធិស្ឋាន
# គឺជាការនាំយកស្ថានសួគ៌មកផែនដី
## *មេរៀនទី ៥: សេចក្តីជំនឿបំពេញលើសេចក្តីអធិស្ឋាន*

### I. ការអធិស្ឋានដោយមានការជឿជាក់

ព្រះគម្ពីរ ១យ៉ូហាន ៥:១៤-១៥

យើងមាន "ការជឿជាក់" លើព្រះ ។ តម្លៃនៃការសន្យាគឺមានត្រឹមតែសេចក្តីល្អ ដូចជាសេចក្តីសុចរិតរបស់មនុស្សដែលបានប្រទានឱ្យនូវសេចក្តីសន្យានោះ ។ ព្រះទ្រង់មិនដែលមានការធ្លាក់ចុះបានទេ ។ ព្រះបន្ទូលនៃទ្រង់គឺស្ថិតស្ថេរនៅជាដរាប ។ ដូច្នេះ យើងអាចមានការជឿជាក់លើទ្រង់ ។ វាគឺជាការសំខាន់ ក្នុងការចំណាយពេលស្តាប់។ នៅពេលដែលយើងទទួលនូវការបើកសម្តែងពីពាក្យ រេម៉ា មកពីទ្រង់ នោះយើងស្គាល់ពីបំណងព្រះហឫទ័យរបស់ទ្រង់ នៅក្នុងស្ថានការណ៍ដ៏ពិសេសនោះ ។ អញ្ចឹង យើងទូលសូមដល់ព្រះអង្គទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ ហើយទ្រង់នឹងស្តាប់ឮ ព្រមទាំងបានយល់ព្រមតាមពាក្យទូលសូមនោះ ។ "យើងអាចដឹងថា យើងបានអ្វីដែលយើងបានទូលសូមពីទ្រង់ហើយ" ។

### ក. ការទូលសូម

មានការអធិស្ឋានជាច្រើន ដែលមិនបានទទួលនូវចម្លើយពីព្រោះពួកគេមិនបានអធិស្ឋាន ។

ព្រះគម្ពីរយ៉ាកុប ៤:២ខ

តើលោកអ្នកបានស្រែកសូមទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ហើយឬនៅ? តើលោកអ្នកបានទទួលនូវការបើកសម្តែងពីបំណងព្រះហឫទ័យរបស់ទ្រង់ហើយឬនៅ? អញ្ចឹងតើលោកអ្នកបានទូលសូម តាមបំណងព្រះហឫទ័យរបស់ទ្រង់ហើយឬនៅ?

ព្រះគម្ពីរម៉ាថាយ ២១:២២

### ខ. ការអធិស្ឋានដោយជំនឿ

"នៅក្នុងគ្រប់ការទាំងអស់" គឺរួមទាំងរបស់គ្រប់យ៉ាង ។ សំណួរគឺ តើលោកអ្នកជឿថា យើងនឹងបានទទួលអ្វីដែលយើងបានទូលសូមឬទេ? ព្រះទ្រង់មានសេចក្តីសន្យា ។ ព្រះទ្រង់មិនដែលកុហកទេ ។ ជឿគឺជាសេចក្តីជំនឿ ។ តើលោកអ្នកជឿឬទេ? តើលោកអ្នកបានទទួលនូវ រេម៉ា ហើយឬនៅ? ខ្ញុំដឹងថា ព្រះទ្រង់អាចធ្វើគ្រប់ទាំងអស់បាន ប៉ុន្តែ ព្រះបន្ទូលដដែលក៏បានចែងថា គ្រប់ទាំងអស់គឺសម្រេចបានដល់អស់អ្នកណាដែលជឿ ។

ព្រះគម្ពីរម៉ាកុស ៩:២៣

### គ. សេចក្តីជំនឿចូលមកតាមរយៈព្រះបន្ទូល

លោកអ្នកអាចជឿបាន ប្រសិនបើចំណាយពេលស្តាប់ឮពាក្យរេម៉ា ។ សេចក្តីចូលមកដោយការស្តាប់ឮព្រះបន្ទូលព្រះ។

ព្រះគម្ពីររ៉ូម ១០:១៧

សេចក្តីអធិស្ឋានគឺជា "ថ្លែងប្រាប់" ឬជា "ការនិយាយ" សេចក្តីជំនឿនោះបានចូលមកក្នុងវិញ្ញាណរបស់យើង ។

### ឃ. ព្រះទ្រង់ជាប្រភេទនៃសេចក្តីជំនឿ

ព្រះគម្ពីរម៉ាកុស ១១:២២-២៤

មានសេចក្តីជំនឿនៅក្នុងព្រះ ឬក៏មានព្រះដែលទ្រង់ជាប្រភេទនៃសេចក្តីជំនឿនោះឯង ។ នេះគឺជាសេចក្តីជំនឿដែល

អាចនិយាយទៅកាន់ភ្នំនៃកាលៈទេសៈបាន ។ នេះគឺជាសេចក្តីជំនឿដែលមិនមានបន្ទប់ឱ្យមានការសង្ស័យ នៅក្នុងចិត្តរបស់យើងបានឡើយ ។នេះគឺជាសេចក្តីជំនឿថា រឿងរ៉ាវដែលយើងនិយាយទាំងអស់នោះ គឺនៅពេលដែលយើងអធិស្ឋានវាចូលឆ្លងកាត់មកហើយ ។

នេះគឺជាសេចក្តីជំនឿដែលជឿថា យើងនឹងទទួលពួកវានៅពេលដែលយើងអធិស្ឋាន មិនមែនយើងនឹងទទួលវាខ្លះៗនៅពេលខ្លះក្នុងពេលខាងមុខនោះទេ ។ វាគឺជាសេចក្តីជំនឿដែលជឿថា យើងបានទទួលរួចទៅហើយនៅក្នុងតំបន់ខាងឯវិញ្ញាណក្នុងពេលយើងបានអធិស្ឋានភ្លាមៗនោះទេ ។

នេះគឺជាសេចក្តីជំនឿដែលជឿថា អ្វីដែលជាការទទួលស្គាល់នៅក្នុងតំបន់ខាងឯវិញ្ញាណនោះ គឺនឹងត្រូវបានទទួលនូវការបើកសម្តែងនៅក្នុងតំបន់ខាងឯធម្មជាតិវិញ ។

នេះគឺជាសេចក្តីជំនឿដែលជឿថា យើងនឹងទទួលនូវអ្វីដែលយើងបានទូលសូមហើយនោះ នៅក្នុងសេចក្តីអធិស្ឋានដែលជឿថា វានឹងត្រូវឆ្លងកាត់ចូលមក ។

សេចក្តីសង្ស័យគឺចាប់កំណើត នៅក្នុងគំនិតខាងធម្មជាតិរបស់យើង គឺនៅក្នុងការគិតរបស់យើងនោះឯង ។ ចូរធ្វើការបដិសេធន៍នូវគំនិតនោះ និងជឿលើតំបន់ខាងឯវិញ្ញាណដែលធ្វើឱ្យគាប់ដល់ព្រះហឫទ័យព្រះ ហើយនិងបានត្រឡប់មកជាសាច់រឿង និងជាការពិតនោះឯង ។

អ្វីដែលមាននោះគឺបានផ្ទង់ចិត្តទៅលើតំបន់ខាងឯវិញ្ញាណនោះឯង ។ ព្រះទ្រង់មិនកុហកទេ ។ សមរភូមិគឺត្រូវតែបានទទួលនូវជ័យដោយវិញ្ញាណ ។ ព្រះបន្ទូលរបស់ព្រះគឺមិនអាចធ្លាក់ចុះបានឡើយ ។

## II. ព្រះទ្រង់បានទទួលខុសត្រូវចំពោះសេចក្តីជំនឿ

ទាំងអស់នោះហើយគឺដែលយើងទទួលមកពីព្រះ គឺតាមរយៈសេចក្តីជំនឿ ។ យើងបានទទួលនូវសេចក្តីសង្គ្រោះ ភាពយុត្តិធម៌ ការគោរពប្រតិបត្តិ និងភាពបរិសុទ្ធដោយសេចក្តីជំនឿ ។ យើងទទួលនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដោយនូវសេចក្តីជំនឿ ។ យើងបានទទួលនូវការប្រោសឱ្យជាគឺដោយនូវសេចក្តីជំនឿ ។ យើងមានការពិសោធន៍នូវការធ្វើការអស្ចារ្យនៅក្នុងជីវិតរបស់យើង គឺដោយសារសេចក្តីជំនឿ ។ យើងបានទទួលនូវជ័យជម្នះគឺដោយសារសេចក្តីជំនឿ ។

សេចក្តីជំនឿគឺជាការជឿ និងប្រព្រឹត្តតាមព្រះបន្ទូលព្រះដោយគ្មានសំណួរ ឬក៏ការព្យាយាមរកការប្រៀបប្រដូចណាមកដោះស្រាយឡើយ ។

### ក. សេចក្តីជំនឿគឺជាខ្លឹមសារ

ព្រះគម្ពីរហេព្រើរ ១១:១

សេចក្តីជំនឿគឺជឿថា យើងយើងបានទទួលនូវ"ខ្លឹមសារ"រួចហើយ ។ វាគឺជាការបញ្ជាក់ភស្តុតាងទៅលើរឿងរ៉ាវ គឺមិនមែនដោយការមើលឃើញតាមភ្នែកខាងធម្មជាតិ របស់យើងនោះទេ ។

ចូរចងចាំថា សេចក្តីសង្ឃឹមចែងមកថា "ខ្ញុំនឹងបានទទួលនៅពេលខ្លះ" ។ សេចក្តីជំនឿចែងមកថា "ខ្ញុំបានទទួលវានៅពេលឥឡូវនេះ" ។ លោកអ័ប្រាហាំបានជឿលើព្រះ គឺនៅពេលដែលគាត់បាននៅក្នុងផ្នែកខាងធម្មជាតិ ដែលវាមិនអាចធ្វើបាននោះ ។

ព្រះគម្ពីររ៉ូម ៤:១៦-២២

លោកអ័ប្រាហាំបានហៅរឿងទាំងនោះ ដែលមិនមាននៅកន្លែងដែលពួកគេមាន ។ នេះគឺជាសេចក្តីអធិស្ឋានដោយជំនឿ ។ នេះគឺជាសេចក្តីជំនឿដែលជឿថា យើងបានទទួល គឺនៅពេលដែលយើងអធិស្ឋាន តាមរយៈបំណងព្រះហឫទ័យដែលបានបើកសម្តែងមកពីព្រះនោះឯង ។ យើងត្រូវតែធ្វើលំហាត់ពីសាចលដុំនៃសេចក្តីជំនឿរបស់យើង ។ លោកអ័ប្រាហាំ គឺមានកម្លាំងដោយនូវសេចក្តីជំនឿ ។

លោកថូម៉ាសគឺជាម្នាក់ ក្នុងចំណោមពួកសិស្សទាំង១២នាក់ មិនដូចជាលោកអ័ប្រាហាំទេ គឺគាត់បានមានប្រសាសន៍ថា ប្រសិនបើខ្ញុំអាចមើលឃើញ និងមានបទពិសោធន៍ទៅលើការនោះ បន្ទាប់មក ខ្ញុំអាចជឿលើវាបានហើយ ។

## ខ. សេចក្តីជំនឿគឺជាការមើលឃើញដោយវិញ្ញាណ

ព្រះគម្ពីរយ៉ូហាន ២០:២៤-២៩

លោកថូម៉ាសគឺបានពឹងពាក់ ទៅលើតែការមើលឃើញខាងធម្មជាតិរបស់គាត់ប៉ុណ្ណោះ ទើបគាត់បាននិយាយថា ប្រសិនបើខ្ញុំមិនបានឃើញទេ នោះខ្ញុំនឹងមិនជឿឡើយ ។ ក្នុងការអធិស្ឋានជាសេចក្តីអធិស្ឋានដោយសេចក្តីជំនឿ នោះយើងមិនអាចស្ថិតនៅក្នុងការមិនជឿឡើយ ។ សេចក្តីជំនឿគឺជាការមើលឃើញខាងវិញ្ញាណ ។

បើគ្រាន់តែជាសាច់រឿងខាងផ្នែកសម្ភារៈ គឺជាពិតចំពោះមនុស្សខាងធម្មជាតិ គឺសូម្បីតែសាច់រឿងខាងវិញ្ញាណដែលពិតប្រាកដចំពោះមនុស្សខាងវិញ្ញាណក៏ដោយ ។

ព្រះគម្ពីរ ១កូរិនថូស ២:១៣-១៤

## គ. សេចក្តីជំនឿ គឺនៅពេលឥឡូវនេះ

សេចក្តីអធិស្ឋានដែលយើងបានអធិស្ឋាន ដោយសេចក្តីជំនឿ នោះគឺមិនតម្រូវឱ្យមានការបើកសម្តែងភ្លាមៗ នៅក្នុងតំបន់ខាងឯធម្មជាតិនោះ ។ "សេចក្តីជំនឿនៅពេលឥឡូវនេះ" គឺជាការបញ្ជាក់ពីរឿងរ៉ាវ គឺមិនមែនជាការមើលឃើញដោយភ្នែកខាងឯធម្មជាតិរបស់យើងមោះទេ ។

ព្រះគម្ពីរហេព្រើរ ១១:៣

ព្រះគម្ពីរ ២កូរិថុស ៤:១៨

តើយើងអាចមើលឃើញ រឿងរ៉ាវដែលយើងមិនបានឃើញនោះដោយវិធីណា? យើងមើលតាមរយៈភ្នែកខាងឯវិញ្ញាណរបស់យើង ហើយក៏មើលឃើញរបស់ដ៏ស្ថិតស្ថេរនោះ ។

## ឃ. សេចក្តីជំនឿ គឺបានតាំងមូលដ្ឋានលើបំណងព្រះហឫទ័យរបស់ព្រះ ។

សេចក្តីជំនឿគឺបានបំពេញ នូវសេចក្តីអធិស្ឋាន ដែលបានផ្តោតទៅលើបំណងព្រះហឫទ័យរបស់ព្រះ ដែលបានសម្រេចនៅស្ថានសួគ៌ដែរ ។

ព្រះគម្ពីរលូកា ១១:១-២

ព្រះគម្ពីរកូល៉ុស ៣:១-២

សេចក្តីអធិស្ឋានដោយជំនឿ គឺជាសេចក្តីអធិស្ឋានដែលមានសម្លេងចូលទៅក្នុងរឿងរ៉ាវនៃនគរសស្ថានសួគ៌ ជាមួយនឹងការយល់ដឹងខាងវិញ្ញាណរបស់យើង ហើយបានទទួលនូវការបើកសម្តែងពីបំណងព្រះហឫទ័យរបស់ព្រះ ដែលបានសម្រេច "ដូចជានៅស្ថានសួគ៌" ហើយនោះដែរ នោះយើងនឹងនាំមកដោយក្លាហាននូវបំណងព្រះហឫទ័យរបស់ព្រះ ឱ្យបាន

សម្រេចនៅផែនដី តាមអ្វីដែលយើងនិយាយនៅពេលយើងអធិស្ឋាននោះឯង ។

## III. ចរឿបាយក្នុងការអធិស្ឋាន

### ក. ការអធិស្ឋានដោយនូវសិទ្ធិអំណាព្រះយេស៊ូវ

នៅពេលដែលយើងអធិស្ឋាន ដោយនូវព្រះនាមព្រះយេស៊ូវ នោះគឺយើងបានអធិស្ឋានដោយនូវសិទ្ធិអំណាចរបស់ទ្រង់នគឺដោយការប្រើនូវ "អំណាចនៃស្នាក្តី" របស់ទ្រង់នោះឯង ។ ដូច្នេះ នៅពេលដែលយើងអធិស្ឋានដោយនូវព្រះនាមព្រះយេស៊ូវ នោះយើងអាចអធិស្ឋានបានត្រឹមតែអ្វី ដែលនៅក្នុងស្ថានការណ៍នោះប៉ុណ្ណោះ ។

ព្រះគម្ពីរយ៉ូហាន ១៦:២៣ខ

ពេលដែលខ្ញុំមានអាយុ៣៣ឆ្នាំ នោះលោកវេជ្ជបណ្ឌិតរបស់ខ្ញុំ បាននិយាយថា ខ្ញុំជិតស្លាប់ហើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំបានរុករកឱ្យឃើញថា ព្រះបន្ទូលបើកសម្តែងថាវាគឺជាបំណងព្រះហឫទ័យរបស់ព្រះ ទៅលើរបស់គ្រប់យ៉ាងដែខ្ញុំបានត្រូវតែមានសេចក្តីចម្រុងចម្រើន
និងមានសុខភាពល្អ នោះឯង ។

ព្រះគម្ពីរ ៣យ៉ូហាន ខ.២

ចំពោះការបើកសម្តែង ពីបំណងព្រះហឫទ័យនៃព្រះនោះគឺត្រូវបានតាំងឡើងនៅក្នុងនគរស្ថានសួគ៌ ឪពុករបស់ខ្ញុំបានធ្វើការអធិស្ឋានសម្រាប់ការប្រោសឱ្យជាដល់ខ្ញុំ ហើយខ្ញុំក៏បានជាជាបរិបូរ ដោយអំណាចចេស្តានៃព្រះ ។ ដើម្បីអធិស្ឋានដោយសេចក្តីជំនឿ យើងត្រូវការស្តាប់ឮមកពីព្រះ និងត្រូវបានជាពិសេសដោយនូវការអធិស្ឋានរបស់យើងនោះឯង ។ ប្រសិនបើយើងស្គាល់ពីបំណងព្រះហឫទ័យ នោះយើងអាចនាំមកនូវបំណងព្រះហឫទ័យរបស់ព្រះ ចូលទៅក្នុងគ្រប់ទាំងស្ថានការណ៍នោះឯង ។ ជាកូនសោរនោះ គឺត្រូវតែអធិស្ឋានតាមបំណងព្រះហឫទ័យរបស់ព្រះ នៅក្នុងគ្រប់ទាំងកាលៈទេសៈដែលយើងអធិស្ឋាននោះ ។

### ខ. ការអធិស្ឋានដោយព្រះវិញ្ញាណ

១. **តើវាជាល្អភាពដើម្បីដឹង ហើយអធិស្ឋានទៅតាមបំណងព្រះហឫទ័យនៃព្រះ ក្នុងគ្រប់ស្ថានការណ៍ទាំងអស់នោះឬ?**

ព្រះគម្ពីររ៉ូម ៨:២៦-២៧

ព្រះវិញ្ញាណអង្គទ្រង់ក៏ជួយអង្វរជំនួសយើង ទៅតាមព្រះហឫទ័យរបស់ផងព្រះ នៅពេលដែលយើងអធិស្ឋានដោយវិញ្ញាណនោះ ។

ព្រះគម្ពីរ ១កូរិនថូស ១៤:១៤-១៥

ដូច្នេះ បើខ្ញុំអធិស្ឋានដោយភាសាដទៃ នោះគឺព្រះវិញ្ញាណបរិសុទ្ធ ទ្រង់បានអធិស្ឋានតាមរយៈវិញ្ញាណរបស់ខ្ញុំ គឺតាមរយៈបំណងព្រះហឫទ័យរបស់ព្រះវរបិតា ។ បន្ទាប់មក លោកសាវ័កប៉ុលមានប្រសាសន៍ថា គាត់មិនបានចាប់ផ្តើមអធិស្ឋាន ដោយប្រាជ្ញារបស់គាត់នោះទេ ។ ប៉ុន្តែ លោកសាវ័កប៉ុលបាននិយាយពីប្រាជ្ញារបស់គាត់ថា មិនបានបង្កើតផលទៅវិញ ដូច្នេះ តើគាត់បានអធិស្ឋានដោយប្រាជ្ញាឬ?

នៅពេលដែលយើងអធិស្ឋានដោយវិញ្ញាណ នោះការបើកសម្តែងនឹងត្រូវបានប្រទានឱ្យ ដោយនូវព្រះវិញ្ញាណបរិសុទ្ធ ។ ក្នុងមួយរំពេចនោះឯង យើងនឹងស្តាប់ឮដោយខ្លួនឯង នូវការអធិស្ឋានពីរឿងរ៉ាវនៅ